**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឈុន សន្តិភាព**

**លោក ហេង គឹមអ៊ួ**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំ **ឈុន សន្តិភាព** និងខ្ញុំបាទ **ហេង គីមអ៊ី** សូមសម្តែងការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត បានចិញ្ចឹមបីបាច់ថែរក្សា និងបានផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មានកូនឱ្យមានសេចក្តីព្យាយាមក្នុងជីវិត។ លោកបានធ្វើការចំណាយពេលវេលា កំលាំងកាយ ចិត្ត និងធនធានយ៉ាងច្រើនដោយមិនគិតពីការនឿយហត់មិនដែលពោលពីទុក្ខលំបាកគ្រប់បែបយ៉ាងដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់កូនឱ្យទទួលបាននូវចំណេះដឹងដ៏ប្រពៃថ្លៃថ្លាសម្រាប់ជាស្ពានចម្លងខ្លួនឯង គ្រួសារ ក៏ដូចជាសង្គមជាតិ។

យើងខ្ញុំសូមថ្លែងអណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឌិត មុន្ទី** ប្រធានតុលាការកំពូល ព្រមទាំងថ្នាក់ដឹកនាំ **ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរាជការនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល** ដែលបានអនុញ្ញាតឱ្យយើងខ្ញុំចុះទៅសិក្សាស្រាវជ្រាវឯកសារនៅតុលាការកំពូល។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ ព្រមទាំង**សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**ទាំងអស់ដែលបានលះបង់នូវរាល់កម្លាំងកាយ កម្លាំងចិត្តក្នុងការដឹកនាំបង្ហាត់បង្រៀន ដើម្បីផ្តល់នូវចំណេះដឹងថ្មីៗ និងដំបូន្មានល្អៗដល់យើងខ្ញុំទាំងអស់គ្នា។ តាមរយៈគុណោបការៈរបស់អស់លោក ទើបធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងល្អៗ ដែលនាំឱ្យយើងអាចបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យនាពេលនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តមបណ្ឌិត ច័ន្ទ រេស្មី** ជាសាស្ត្រាចារ្យផ្នែកនីតិព្រហ្មទណ្ឌ និងជាចៅក្រមតុលាការកំពូល ទន្ទឹមនឹងនេះក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកមេធាវី សូ សឡុមន្តិ** ដែលបានផ្តល់ជាមតិយោបល់ និងផ្តល់នូវឯកសារជាច្រើនសម្រាប់ការស្រាវជ្រាវមួយនេះ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោក ហោ សុវ័ណ្ណា** ជាសាស្ត្រាចារ្យណែនាំ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្តដើម្បីជួយណែនាំផ្តល់នូវដំបូន្មាន កែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានជោគជ័យគួរជាទីមោទនៈភាពនាពេលនេះ។ ជាកិច្ចបញ្ចប់ យើងខ្ញុំសូមជូនពរដល់អស់លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានឱ្យជួបប្រទះតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានសុខភាពល្អ ជាពិសេសសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជាដែលទាក់ទងទៅនឹងផ្នែកនីតិវិធីព្រហ្មទណ្ឌ។ ហើយដោយបានសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនពុំសូវមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីនីតិវិធីនៃការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ប៉ុន្មានទេ។ ជាងនេះទៅទៀត ឯកសារដែលសរសេររៀបរាប់លម្អិតអំពីនីតិវិធីឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាពិសេសនីតិវិធីនៃបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌនេះ ក៏ពុំសូវសម្បូរបែបប៉ុន្មាននោះដែរ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាតម្រូវការរបស់មិត្តអ្នកអាន និងការស្រលាញ់ពេញចិត្តផ្ទាល់ខ្លួន ជាពិសេសដើម្បីចងក្រងទុកជាឯកសារក្រោយពេលយើងបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ យើងក៏សម្រេចចិត្តកំណត់យកប្រធានបទស្តីពី **"នីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ"** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ តាក់តែងជាសារណានេះឡើង។

យើងពិតជាមានមោទនៈភាពយ៉ាងខ្លាំងចំពោះស្នាដៃមួយនេះ ដោយហេតុថាវាជាការស្រាវជ្រាវមួយថ្មី ហើយជាងនេះទៅទៀតយើងអាចបង្កើតជាស្នាដៃនេះឡើងខណៈពេលដែលយើងខ្ញុំមានការលំបាកក្នុងការស្វែងរកឯកសារនានាដែលពាក់ព័ន្ធទៅនឹងនីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌនេះ និងសរសេរឱ្យគ្រប់តាមចំនួនកំណត់របស់សាកលវិទ្យាល័យ។ ក្នុងស្នាដៃនេះផងដែរ យើងបានសរសេររៀបរាប់អំពីទ្រឹស្តីដែលមានចែងនៅក្នុងច្បាប់ អំពីការអនុវត្តជាក់ស្តែងតាមរយៈការចុះទៅស្រាវជ្រាវនៅតុលាការកំពូល ដើម្បីយកឯកសារផ្សេងៗជាច្រើនទៀតដែលពាក់ព័ន្ធយកមកធ្វើជាឧបសម្ព័ន្ធ។ យើងមានការសង្ឃឹម និងជឿជាក់យ៉ាងមុតមាំក្នុងចិត្តថាស្នាដៃនេះពិតជាអាចរួមចំណែកក្នុងការផ្តល់នូវចំណេះដឹងផ្នែកច្បាប់ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន សិស្ស និស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយ ហើយក៏ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ និងនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែរីកចម្រើនមួយកម្រិតថែមទៀតដែរ។

ជាចុងក្រោយនេះ យើងសូមការខន្តីអភ័យទោសទុកជាមុនអំពីសំណាក់ សិស្ស និស្សិត មិត្តអ្នកអាន សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវ នូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយ អចេតនាត្រង់ប្រការណាមួយតាមរយៈការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យ ឬមិនត្រឹមត្រូវត្រង់ចំណុចណាមួយនៃស្នាដៃនេះ។ យើងខ្ញុំរីករាយ និងទទួលយកនូវការរិះគន់ទាំងឡាយ ដើម្បីស្ថាបនាឱ្យការស្រាវជ្រាវកាន់តែល្អឡើងមួយកម្រិតថែមទៀត។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ............ ១

## ជំពូកទី១
## តុលាការនៃបណ្តឹងសាទុក្ខ

**១. ១. និដ្ឋភាពទូទៅនៃតុលាការកំពូល** ............ ៣

១. ១. ១. ប្រវត្តិតុលាការកំពូល ............ ៣

១. ១. ២. បច្ចុប្បន្នភាពនៃតុលាការកំពូល............ ៤

**១. ២. តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល** ............ ៦

១. ២. ១. តុលាការកំពូល............ ៦

១.២.១.១.សមាសភាព ............ ៧

១.២.១.២.សភាជំនាញ ............ ៧

១.២.១.៣.សមត្ថកិច្ច ............ ៩

១. ២. ២. មហាអយ្យការអមតុលាការកំពូល ............ ១១

១.២.២.១.សមាសភាព ............ ១១

១.២.២.២.សមត្ថកិច្ច ............ ១៣

១. ២. ៣. អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ............ ១៤

១.២.៣.១.សមាសភាព............ ១៤

១.២.៣.២.មុខងារ............ ១៥

## ជំពូកទី២
## នីតិវិធីនៃបណ្តឹងសាទុក្ខ

**២. ១. សញ្ញាណនៃបណ្តឹងសាទុក្ខ**............ ២២

២. ១. ១. អំពីបណ្តឹងសាទុក្ខ............ ២២

២. ១. ២. ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ ............ ២២

២. ១. ៣. អានុភាពបង្អង់នៃបណ្តឹងសាទុក្ខ............ ២៣

**២. ២. លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ**............ ២៤

២. ២. ១. មូលហេតុនៃបណ្តឹងសាទុក្ខ............ ២៤

២. ២. ២. បុគ្គលដែលអាចប្តឹងសាទុក្ខ ............ ២៥

២. ២. ៣. រយៈពេលនៃបណ្តឹងសាទុក្ខ............ ៣០

**២. ៣. ចំណាត់ការនៃបណ្តឹងសាទុក្ខ** ........ ៣១
២. ៣. ១. ការចុះបញ្ជីសំណុំរឿង ........ ៣១
២. ៣. ២. រយៈពេលធ្វើសារណា ........ ៣១
២. ៣. ៣. ការចាត់តាំងចៅក្រមរបាយការណ៍ ........ ៣២
២. ៣. ៤. ការបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋាន ........ ៣៣

## ជំពូកទី៣

## ការជំនុំជម្រះ និងការបោះបង់ចោលបណ្តឹងសាទុក្ខ

**៣. ១. នីតិវិធីជំនុំជម្រះ** ........ ៣៧
៣. ១. ១. ការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការ ........ ៣៧
៣. ១. ២. ការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១ ........ ៣៨
៣.១.២.១.ការបដិសេធដោយគ្មានការបង្វិលសំណុំរឿង ........ ៣៩
៣.១.២.២.ការបដិសេធដោយមានការបង្វិលសំណុំរឿង ........ ៣៩
៣. ១. ៣. ការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ ........ ៣៩
៣. ១. ៤. អានុភាពនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទី២ ........ ៤០
**៣. ២. ការបោះបង់ចោលបណ្តឹងសាទុក្ខ** ........ ៤១
៣. ២. ១. អំពីការបោះបង់ចោលបណ្តឹងសាទុក្ខ ........ ៤១
៣. ២. ២. របៀបបោះបង់ចោលបណ្តឹងសាទុក្ខ ........ ៤១
៣. ២. ៣. អានុភាពនៃការដកបណ្តឹងសាទុក្ខ ........ ៤២
**សេចក្តីសន្និដ្ឋាន** ........ ៤៣
**មតិយោបល់ និងសំណូមពរ** ........ ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្នុងសម័យបុរាណ ការគ្រប់គ្រងរដ្ឋ ឬក្រុមជនជាតិមានលក្ខណៈជាក្រុមមេកន្ទ្រាញ ឬស្តេច។ ទស្សនវិជ្ជានៃការគ្រប់គ្រងមានលក្ខណៈទៅតាមក្រុមតាមតំបន់ ឬភូមិភាគនៃដែនដីរដ្ឋបាលរបស់ក្រុមជនជាតិ។ គោលការណ៍បែងចែកអំណាច គឺដើម្បីប្រឆាំងនឹងរបបផ្តាច់ការដែលអំណាចមាននៅលើតែបុគ្គល ឬមនុស្សមួយក្រុមតូច។ យោងតាមគោលការណ៍របស់អ្នកប្រាជ្ញ ម៉ុង តេស្គីយើ (MONTESQUIEU) ដ៏ល្បីគឺ "ស្មារតីច្បាប់ -THE SPIRIT OF LAWS ឆ្នាំ១៧២៨-១៧៤៨ ដែលត្រូវបានគេបោះពុម្ពនៅឆ្នាំ១៧៤៨ ។ ទ្រឹស្តីបែងចែកអំណាចរបស់ MONTESQUIEU [1] គឺសមិទ្ធិផលនៃទ្រឹស្តីបែងចែកអំណាចរបស់លោក អារីស្តូត និងប្លាតុង បន្ទាប់លោក អាគ្វីនីស និង ចន ឡុក។ ទ្រឹស្តីរបស់លោក ម៉ុង តេស្គីយើ (MONTESQUIEU) បានបែងចែកអំណាចជា ៣ (បី) គឺ អំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ហេតុនេះហើយ អំណាចទាំងបីនេះត្រូវមានច្បាប់កំពូលជាអ្នកធានាផ្គត់ផ្គង់ដោយធ្វើយ៉ាងណាឱ្យស្ថាប័នអំណាចនីមួយៗមានសកម្មភាពទំនាក់ទំនងគ្នាដោយឯករាជ្យ។

អំណាចតុលាការជាអំណាចឯករាជ្យ [2] ហើយព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ [3] ។ គ្មានអង្គការណាមួយនៃនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ[4]។ ការជម្រះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធីជាធរមាន [5] ដោយអំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

តុលាការកំពូល គឺជាសាលាជម្រះក្តីចុងក្រោយគេបង្អស់ ហើយសមត្ថកិច្ចរបស់តុលាការកំពូលជំនុំជម្រះគ្រប់រឿងក្តីទាំងអស់ដែលត្រូវបានប្តឹងឧបាស្រ័យមកកាន់តុលាការកំពូល ហើយត្រូវបានដោះស្រាយដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល *(ចំពោះបណ្តឹងសាទុក្ខក្នុងរឿងក្តីរដ្ឋប្បវេណី ត្រូវទទួលបន្ទុកដោយសភារដ្ឋប្បវេណីនៃតុលាការកំពូល)*។ ជាទូទៅនៅពេលដែលភាគីមានការមិនសុខចិត្តទៅនឹងការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ការប្តឹងតវ៉ាទៅនឹងការសម្រេចសេចក្តីនៃសាលាឧទ្ធរណ៍ គឺត្រូវតែប្តឹងសាទុក្ខមកកាន់តុលាការកំពូលដើម្បីឱ្យតុលាការកំពូលធ្វើការបដិសេធនូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។

---

[1] លោក Montesquieu កើតនៅ Bordeaux ប្រទេសបារាំង ធ្លាប់ជាទីប្រឹក្សាសហភាព ហើយបន្ទាប់មកជា ប្រធានសភា Bordeaux បានសរសេរសៀវភៅប្រមាណ ៣១ ក្បាល ហើយមួយក្បាលៗមានប្រមាណពី ១៥-២០ ជំពូក។

[2] មាត្រា ១២៨ ថ្មី ( មាត្រា១០៩ ចាស់) កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[3] មាត្រា ១៣២ ថ្មី (មាត្រា ១១៣ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[4] មាត្រា ១៣០ ថ្មី (មាត្រា ១១១ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[5] មាត្រា ១២៩ ថ្មី (មាត្រា ១១០ ចាស់) កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

នៅក្នុងសៀវភៅសារណានេះគឺបានលើកឡើងនូវប្រធានបទស្តីពី "**នីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ**" ដើម្បីយកមកធ្វើការពន្យល់បង្ហាញ និងរៀបរាប់អំពីនីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌនៃតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត នៅពេលដែលនិយាយអំពីបណ្តឹងសាទុក្ខ សំនួរដែលត្រូវចោទសួរមានដូចជាៈ

-តើអ្វីទៅជាបណ្តឹងសាទុក្ខ?

-តើដើម្បីធ្វើបណ្តឹងសាទុក្ខមួយនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ថាតើត្រូវធ្វើដូចម្តេច?

-តើនីតិវិធីនៃការជំនុំជម្រះទៅលើបណ្តឹងសាទុក្ខនៃតុលាការកំពូល មានលំហូរនៃនីតិវិធីយ៉ាងដូចម្តេច?

ចម្លើយនូវសំនួរទាំងនេះ គឺមានការបកស្រាយរៀបរាប់នៅទំព័របន្ទាប់ពីនេះប៉ុន្តែមុននឹងឈានទៅដល់ការបកស្រាយនូវសំនួរទាំងនេះ យើងខ្ញុំសូមធ្វើការប្រកាសនូវប្លង់នៃសារណាបញ្ចប់ការសិក្សានេះ ។ ប្លង់នៃសៀវភៅមួយក្បាលនេះត្រូវបានបែងចែកជា ០៣ជំពូកៈ

ជំពូកទី១ និយាយអំពីតុលាការនៃបណ្តឹងសាទុក្ខ ដែលនៅក្នុងជំពូកនេះនឹងមានការរៀបរាប់អំពីទិដ្ឋភាពទូទៅនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ។

ជំពូកទី២ និយាយអំពីនីតិវិធីបណ្តឹងសាទុក្ខនៃតុលាការកំពូល ដែលនៅក្នុងជំពូកនេះ គឺមានការរៀបរាប់អំពីលំហូរនៃនីតិវិធី និងចំណាត់ការជាក់ស្តែងដែលតុលាការកំពូលមានសមត្ថកិច្ចទៅលើបណ្តឹងសាទុក្ខ។

ជំពូកទី៣ និយាយអំពីនីតិវិធីជំនុំជម្រះ និងការបោះបង់ចោលបណ្តឹងសាទុក្ខ ដែលនេះគឺជាជំពូកចុងក្រោយនៃសៀវភៅមួយក្បាលនេះហើយនៅក្នុងជំពូកនេះផងដែរ យើងខ្ញុំនឹងធ្វើការរៀបរាប់អំពីនីតិវិធីនៃការជំនុំជម្រះទៅលើបណ្តឹងសាទុក្ខលើកទី១ បណ្តឹងសាទុក្ខលើកទី២ និងការបោះបង់ចោលបណ្តឹងសាទុក្ខ ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា សៀវភៅសារណាដែលបានរៀបរាប់អំពី "**នីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ**" មួយក្បាលនេះជាចំណែកមួយដែលអាចឱ្យអ្នកអាន សិស្ស និស្សិត ឬស្ទេរ ជំនាន់ក្រោយបានដឹង និងទុកជាឯកសារសម្រាប់ស្រាវជ្រាវអំពីនីតិវិធីបណ្តឹងសាទុក្ខនៃតុលាការកំពូល និងនីតិវិធីជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌឱ្យកាន់តែច្បាស់ជាងនេះ។

# ជំពូកទី១

# តុលាការនៃបណ្ដឹងសាទុក្ខ

# ជំពូកទី១

# តុលាការនៃបណ្តឹងសាទុក្ខ

## ១. ១. ទិដ្ឋភាពទូទៅនៃតុលាការកំពូល

### ១. ១. ១. ប្រវត្តិតុលាការកំពូល

តាមប្រវត្តិសាស្ត្រនៅមុនឆ្នាំ ១៨៦៣ ព្រះរាជាណាចក្រកម្ពុជាពុំមានស្ថាប័នតុលាការកំពូលទេ ប៉ុន្តែមានតែព្រះមហាក្សត្រប៉ុណ្ណោះដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចសេចក្តីចុងក្រោយ។ បន្ថែមពីនេះទៅទៀត នៅឆ្នាំ១៨៦៣ ដល់ប្រហាក់ប្រហែលឆ្នាំ១៩០២ ថ្វីត្បិតតែព្រះរាជាណាចក្រកម្ពុជាត្រូវបានស្ថិតនៅក្រោមនឹមអាណានិគមបារាំង និងប្រព័ន្ធច្បាប់បារាំងត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងប្រទេសកម្ពុជាដោយប្រព័ន្ធតុលាការកម្ពុជានាពេលនោះត្រូវបានបែងចែកជាពីរជាន់ គឺជាន់ដំបូងដែលស្ថិតក្រោមការទទួលខុសត្រូវរបស់គណៈកម្មការស្រុក ឯជាន់បន្ទាប់គឺក្រោមសមត្ថកិច្ចរបស់ចៅក្រមដោយមានសាលាឈ្មោះ "លហុ"។ ប៉ុន្តែស្ថាប័នតុលាការកំពូលនៅតែមិនទាន់ត្រូវបានបង្កើតនៅឡើយ ដូច្នេះហើយតួនាទីរបស់ព្រះមហាក្សត្រក្នុងការសម្រេចសេចក្តីចុងក្រោយនៅតែសំខាន់ (*ឧទាហរណ៍ ប្រសិនបើគូជម្លោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ថ្នាក់ស្រុក ឬចៅក្រមទេ ពោលគឺភាគីអាចប្តឹងតវ៉ាទៅព្រះមហាក្សត្រដើម្បីឱ្យទ្រង់ជាអ្នកសម្រេចសេចក្តីចុងក្រោយ*)។ ដូច្នេះការអនុវត្តបែបនេះ នាំឱ្យមានការយល់ឃើញថាជាការចាប់បដិសន្ធិនៃមុខងារតុលាការកំពូល។

នៅឆ្នាំ១៩០២ រចនាសម្ព័ន្ធរបស់តុលាការមានការវិវឌ្ឍន៍យ៉ាងគួរឱ្យកត់សម្គាល់ ដោយប្រព័ន្ធយុត្តិធម៌ ត្រូវបានបែងចែកជា ៣ជាន់រួមមាន សាលាដំបូង, សាលាឧទ្ធរណ៍ និងកុង្សិយ៍សេនាបតី[6] ដែលត្រូវបានដើរតួនាទីជាតំណាងព្រះមហាក្សត្រ និងតួនាទីសំខាន់ក្នុងការពិនិត្យនីតិវិធី និងបញ្ហាផ្លូវច្បាប់។ ហេតុដូច្នេះ នៅពេលនោះប្រព័ន្ធនេះត្រូវបានប្រដូចទៅនឹងគំរូនៃតួនាទីជាតុលាការកំពូល។

ចាប់តាំងពីឆ្នាំ១៩១១ ដល់សម័យរដ្ឋប្រហារឆ្នាំ១៩៧០ រដ្ឋធម្មនុញ្ញដំបូងឆ្នាំ១៩៤៧ ត្រូវបានបង្កើតឡើងដោយរចនាសម្ព័ន្ធតុលាការត្រូវបានរៀបចំ និងកែសម្រួលបែងចែកជាតុលាការជាន់ខ្ពស់បំផុតនៅក្នុងប្រព័ន្ធតុលាការនាពេលនោះគឺ "Court of Cassation"[7] ដែលមានតួនាទីជាអ្នកសម្រេចសេចក្តីចុងក្រោយចំពោះបណ្តឹងតវ៉ា។

បន្ទាប់ពីរដ្ឋប្រហារជោគជ័យនៅឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥មក រដ្ឋធម្មនុញ្ញថ្មីឆ្នាំ១៩៧២ ត្រូវបានបង្កើតឡើងដោយធ្វើប្រជាមតិ ដោយប្រព័ន្ធយុត្តិធម៌មានគំរូដូចទៅនឹងតុលាការនៅសហរដ្ឋអាមេរិក។ ទម្រង់ប្រព័ន្ធតុលាការ ០៤ផ្នែក ត្រូវបានបង្កើតឡើងដោយទ្រទ្រង់ប្រព័ន្ធយុត្តិធម៌ ហើយបានប្រើប្រាស់ឈ្មោះ "តុលាការកំពូល"។ ផ្ទុយមកវិញ ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធតុលាការ ក្នុងរបបប្រល័យពូជសាសន៍ដឹកនាំដោយ

---

[6] ក្រុមជំនុំរាជការផែនដីធំ មានសេនាបតីទាំង៤ ជាចតុស្តម្ភ មានអគ្គមហាសេនាជាអធិបតី សព្វថ្ងៃហៅថា គណៈរដ្ឋមន្ត្រី

[7] Court of Cassation គឺជា តុលាការកំពូល ដែលជាពាក្យប្រើក្នុងប្រទេសបារាំង ។

ប៉ុលពត ឬខ្មែរក្រហមត្រូវបានមិនដំណើរការ មិនតែប៉ុណ្ណោះអ្នកតាក់តែងច្បាប់ ក៏ដូចជាអ្នកមានវិជ្ជាជីវៈច្បាប់ជាច្រើនត្រូវបានសម្លាប់ លើសពីនេះច្បាប់ ឬអត្ថបទច្បាប់ជាច្រើនត្រូវបានកម្ទេចចោលទាំងស្រុង។ ហេតុដូច្នេះបន្ទាប់ពីថ្ងៃជ័យជំនះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលដឹកនាំដោយបក្សកាន់អំណាចនាពេលបច្ចុប្បន្ននេះមានការអភិវឌ្ឍប្រទេសត្រូវបានងើបពីចំណុចសូន្យ និងការបង្កើតប្រព័ន្ធច្បាប់បានជួបប្រទះនូវកង្វះខាតយ៉ាងខ្លាំងក្លាបំផុតនូវធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ជំនួយផ្នែកហិរញ្ញវត្ថុ និងជំនួយផ្នែកបច្ចេកទេស។

នៅឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៥ ប្រព័ន្ធយុត្តិធម៌មានតែមួយជាន់តែប៉ុណ្ណោះ ដោយត្រូវបានហៅថា "តុលាការប្រជាជនខេត្ត-ក្រុង" ប៉ុន្តែនីតិវិធីនៃសវនាការមានតែពីរដំណាក់កាលប៉ុណ្ណោះ ដែលមានតែសវនាការជំហានទី១ និងចុងក្រោយ គឺសវនាការជំហានទី២[8]។

ក្នុងឆ្នាំ១៩៨៥ អនុលោមតាមច្បាប់ក្នុងការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូលដែលត្រូវបានប្រកាសដោយក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥ នោះស្ថាប័នកំពូលនៃប្រព័ន្ធតុលាការត្រូវបានបង្កើតឡើងដោយមានឈ្មោះថា "តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល" ឈ្មោះនេះត្រូវបានបន្តរហូតដល់ដើមឆ្នាំ១៩៩៣។

### ១. ១. ២. បច្ចុប្បន្នភាពនៃតុលាការកំពូល

នៅខែកុម្ភៈ ឆ្នាំ១៩៩៣ ដោយអនុលោមទៅតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣។ នាពេលនោះ តុលាការជាន់ខ្ពស់ក្នុងប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាត្រូវបានបង្កើតឡើងដោយមានឈ្មោះថា " **តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល**" ដូចសព្វថ្ងៃនេះ[9]។

ម្យ៉ាងវិញទៀត បន្ទាប់ពីការបញ្ចប់នៃសង្គ្រាមត្រជាក់ វត្តមាននៃសន្និសញ្ញាទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១[10] និងការមកដល់នៃកងទ័ពអ៊ុនតាក់ (UNTAC) ក្នុងប្រទេសកម្ពុជាមានការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ដែលបង្ហាញការគាំទ្រគណបក្សកាន់អំណាចបច្ចុប្បន្ន (គណបក្សប្រជាជនកម្ពុជា) នោះបាននាំមកនូវសន្តិភាពពេញបរិបូរណ៍ ភាពត្រឹមត្រូវ និងស្ថេរភាពសម្រាប់ប្រទេសជាតិទាំងមូល។ បន្ទាប់មករដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តឡើង និងប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ច្បាប់កំពូលនេះគឺបានបែងចែក

[8] សូមអាន រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ នៃច្បាប់ស្តីអំពីការរៀបចំតុលាការប្រជាជនបដិវត្តខេត្តក្រុង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ និងច្បាប់ស្តីពីការរៀបចំស្ថាប័នតុលាការ និងអយ្យការចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២។

[9] មាត្រា១ នៃស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣

[10] បន្ទាប់ពីបានបញ្ចប់សង្គ្រាមត្រជាក់ ក៏មានវត្តមាននៃសន្និសញ្ញាក្នុងឆ្នាំ១៩៩១ កិច្ចព្រមព្រៀងនេះគឺដើម្បីបញ្ចប់សង្គ្រាមស៊ីវិលរយៈពេលវែងនៅកម្ពុជាដែលបានធ្វើឡើង នៅទីក្រុងប៉ារីស និងចុះហត្ថលេខាដោយភាគីចំនួន ០៤ រួមមាន៖ ១-រដ្ឋាលភិបាលនៃរដ្ឋកម្ពុជា ២-ហ៊ុន ស៊ីនប៉ិច ៣-រណសិរ្សរំដោះជាតិប្រជាជនខ្មែរ និង៤-ខ្មែរក្រហម។

អំណាចជា ០៣ ដាច់ដោយឡែក រួមមានអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ[11]។ ជារួមតួនាទីតុលាការនៅក្នុងប្រទេសកម្ពុជា គឺមានសារៈសំខាន់ណាស់ដើម្បីបង្កើតឱ្យមានស្ថេរភាពសង្គម និងការគោរពនីតិរដ្ឋ ជាពិសេសគឺ តួនាទីកំពូលនៃតុលាការកំពូលដែលជាតុលាការជាន់ខ្ពស់បំផុតនៃប្រព័ន្ធយុត្តិធម៌[12]។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រា ១៣៥ថ្មី (ពីមុនជាមាត្រា ១១៦) បានចែងថា ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ និងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ប៉ុន្តែនៅពេលនោះច្បាប់គោលដែលតាំងនោះគ្រាន់តែជាសេចក្តីព្រាងច្បាប់តែប៉ុណ្ណោះ។ ដូច្នេះហើយរចនាសម្ព័ន្ធតុលាការទាំងមូលនៅតែបន្តដំណើរតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ដោយច្បាប់នេះត្រូវបានប្រើប្រាស់រហូតដល់ឆ្នាំ២០១៤ ទើបច្បាប់នេះត្រូវបាននិរាករណ៍។ ដូច្នេះហើយ តុលាការកំពូលបច្ចុប្បន្នមានអាយុកាលប្រមាណ ២៧ឆ្នាំហើយ។

សម័យបច្ចុប្បន្នរចនាសម្ព័ន្ធតុលាការកំពូលបានបែងចែកទៅតាមបញ្ញត្តិនៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការកំពូល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

តុលាការកំពូលមានចៅក្រមសរុបមិនលើសពី ២៥ រូប។ រចនាសម្ព័ន្ធតុលាការកំពូល[13]ត្រូវរៀបចំដំណើរការដោយៈ

១-តុលាការកំពូល

២-មហាអយ្យការអមតុលាការកំពូល

៣-អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

- **ទីតាំង**

**ក-ទីតាំងជាក់ស្តែង**

តុលាការកំពូលមានទីតាំងតែមួយគត់គឺនៅរាជធានីភ្នំពេញ[14]។ បច្ចុប្បន្នតុលាការកំពូលមានអាសយដ្ឋាននៅមហាវិថី សម្តេចសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលជាទីតាំងតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។

**ខ-អាស័យដ្ឋានក្នុងប្រព័ន្ធអ៊ីនធឺណេត**

[11] មាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[12] មាត្រា១២៨ថ្មី (មាត្រា១០៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[13] សូមអានត្រង់ចំណុចជំពូកទី៤ "តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល" នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[14] មាត្រា៩៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

តុលាការកំពូលមានគេហទំព័រផ្លូវការ www.supremecourt.gov.kh ដែលមានការបង្ហាញកម្មវិធីជំនុំជម្រះលើផ្នែកសំណុំរឿងព្រហ្មទណ្ឌ និងផ្នែកសំណុំរឿងរដ្ឋប្បវេណីប្រហែលមួយសប្តាហ៍មុនថ្ងៃជំនុំជម្រះដើម្បីផ្តល់ភាពងាយស្រួល និងបង្កិតសោវ៉ាយុត្តិធម៌ឱ្យជិតប្រជាពលរដ្ឋផងដែរ។ ចំពោះប្រព័ន្ធទំនាក់ទំនងសង្គមតុលាការកំពូលមានឈ្មោះផ្លូវការ "តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល" ក៏បង្ហាញអំពីកម្មវិធីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌ និងសំណុំរឿងរដ្ឋប្បវេណីផងដែរ ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក៏ដូចជាគូភាគីក្នុងការស្វែងរកព័ត៌មានសំណុំរឿងដែលនឹងត្រូវជំនុំជម្រះ[15]។

## ១. ២. តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

### ១. ២. ១. តុលាការកំពូល

បើនិយាយអំពី "តុលាការ" គឺមកពីពាក្យ "តុលា" ប្រែថា ជញ្ជីង ឬ ត្រាជូ, ផ្សំជាមួយ "ការៈ ឬអាការៈ" មានន័យថាការថ្លឹង ការស្ទង់មិនឱ្យល្អៀង ឬអ្នកស្ទង់តម្រង់សេចក្តី ឬកិច្ចការដែលគេជម្រះក្តីគេកាន់យុត្តិធម៌ឱ្យស្មើដោយថ្លឹងដូចជញ្ជីង[16] ក្រសួងជម្រះក្តី ឬចៅក្រម អ្នកវិនិច្ឆ័យក្តី។ ដូច្នេះ "តុលាការ" គឺជាអ្នកកាត់ក្តី ឬស្ថាប័នកាត់ក្តីដែលលើកតម្កើងមុខងារសំខាន់ខាងការថ្លឹងថ្លែងមិនឱ្យល្អៀង។ អំណាចតុលាការជាអំណាចឯករាជ្យ[17] ហើយព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ[18]។ ដោយឡែកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងត្រូវកំណត់អំពីសមាសភាព និងមុខងារ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្តីទាំងអស់ លើសពីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខងារដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា[19]។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ គ្មានអង្គការណាមួយនៃនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ[20]។ អំណាចតុលាការគ្រប់ដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តី

[15] តុលាការកំពូលមានគេហទំព័រផ្ទាល់ ដែលមានឈ្មោះជាភាសាខ្មែរ "តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល"។

[16] វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា, បទសម្ភាសន៍នាទីអក្សសាស្ត្រ សម្តេចព្រះសង្ឃរាជ ជួនណាត, ពោលខាងលើ, ទំព័រ ១៨៤ និងវចនានុក្រមខ្មែរ ទំព័រ ២៥៨ ។ កាលពីសតវត្សទី១៩ ពាក្យ តុលាការ ត្រូវបានគេហៅក្លាយមកជា ត្រលាការ ។

[17] មាត្រា ១២៨ ថ្មី ( មាត្រា១០៩ ចាស់) កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[18] មាត្រា ១៣២ ថ្មី (មាត្រា ១១៣ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[19] មាត្រា ១៣៤ ថ្មី (មាត្រា១១៥ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[20] មាត្រា ១៣០ ថ្មី (មាត្រា ១១១ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

រដ្ឋបាលផងដែរ។ ការជម្រះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធីជាធរមាន[21] ដោយអំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

ប្រធានតុលាការកំពូលត្រូវទទួលបន្ទុកជាអាណាប័កផ្ទេរសិទ្ធិ ក្នុងការគ្រប់គ្រងឥណទានថវិការបស់តុលាការកំពូល។ ឥណទានថវិការបស់តុលាការកំពូល ស្ថិតក្នុងប្រភេទមួយនៃថវិការបស់ក្រសួងយុត្តិធម៌ មានន័យថារដ្ឋផ្តល់ថវិកាផ្គត់ផ្គង់ការគ្រប់គ្រងតុលាការកំពូលតាមរយៈក្រសួងយុត្តិធម៌ ដោយពុំមានការផ្តល់ថវិកាជាលក្ខណៈស្វយ័តឱ្យតុលាការកំពូលទេ។

### ១.២.១.១.សមាសភាព

សមាសភាពនៃតុលាការកំពូលរួមមាន ប្រធានតុលាការកំពូល អនុប្រធានតុលាការកំពូល ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ហើយនឹងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅក្នុងតុលាការកំពូល[22] មាត្រា៥៦ ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ។

ចៅក្រមនៃតុលាការកំពូលមានចំនួនមិនលើសពី ២៥ (ម្ភៃប្រាំ)រូប ដោយគិតទាំងអនុប្រធាន និងចៅក្រមទាំងអស់នៃតុលាការកំពូល។ ប៉ុន្តែយោងតាមតម្រូវការចាំបាច់ចំនួនចៅក្រមនៃតុលាការកំពូលអាចត្រូវកំណត់លើសពីនេះ ដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប្រធានតុលាការកំពូលមានឋានន្តរស័ក្តជាឧត្តមចៅក្រមថ្នាក់ខ្ពស់បំផុត និងជាសមាជិកអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្រឡាបញ្ជីជួយចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និងអយ្យការ។ តួនាទីនិងមុខងាររបស់ក្រឡាបញ្ជីត្រូវកំណត់ក្នុងលក្ខន្តិកៈនៃក្រឡាបញ្ជី[23]។

សមាសភាពរបស់សភានីមួយៗនៃតុលាការកំពូលរួមមានប្រធានសភា ចៅក្រម និងក្រឡាបញ្ជី។ ប្រធានរបស់សភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល។ ចំនួនចៅក្រម ក្រឡាបញ្ជី និងកិច្ចដំណើរការរបស់សភាទាំងនេះត្រូវកំណត់ដោយប្រធានតុលាការកំពូល[24]។

### ១.២.១.២.សភាជំនាញ

សភាជំនាញនីមួយៗនៃតុលាការកំពូលសម្រេចសេចក្តីដោយមានសមាសភាពចៅក្រមចំនួន ០៥ (ប្រាំ) រូប ដែល ០១ (មួយ) រូប ជាប្រធានដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន[25]។ ប្រធានតុលាការកំពូលចាត់វិធានការគ្រប់គ្រងជាចាំបាច់ក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូល និងណែនាំសភាទាំងអស់របស់

[21] មាត្រា ១២៩ ថ្មី (មាត្រា ១១០ ចាស់) កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[22] មាត្រា៥៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[23] មាត្រា៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[24] មាត្រា៥៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[25] មាត្រា៥៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

តុលាការកំពូលឱ្យអនុវត្តច្បាប់ ដោយចេញដីកាសម្រេចដើម្បីចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ចាត់ចែងការងារជំនួសខ្លួនក្នុងករណីចាំបាច់ ដើម្បីទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ និងបទពិសោធន៍ការងារ។ ក្នុងករណីដែលខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឱ្យធ្វើជាប្រធានសភាបាន[26]។

សភាជំនាញនៃតុលាការកំពូល មានដូចជាសភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ ដែលសភានីមួយៗចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល មាត្រា៥៧ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ។ ប៉ុន្តែក្នុងករណីចាំបាច់សភាជំនាញផ្សេងទៀតរបស់តុលាការកំពូលអាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ[27] ។

**សភាជំនាញនៃតុលាការកំពូល មានដូចខាងក្រោម៖**

**ក-សភាព្រហ្មទណ្ឌ**

សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[28]។

**ខ-សភារដ្ឋប្បវេណី**

សភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខ ចំពោះសាលដីកា និងបណ្ដឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ព្រមទាំងលើបណ្ដឹងសាទុក្ខចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្ដីផ្សេងទៀតដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន[29]។

**គ-សភាពាណិជ្ជកម្ម**

សភាពាណិជ្ជកម្មនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខចំពោះសាលដីកា និងបណ្ដឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងក្ដីពាណិជ្ជកម្មរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម[30]។

**ឃ-សភាការងារ**

សភាការងារនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខចំពោះសាលដីកា និងបណ្ដឹង

[26] មាត្រា៦០ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤
[27] មាត្រា៥៧ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤
[28] មាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤
[29] មាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤
[30] មាត្រា៦៥ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

ជំទាស់ចំពោះដីកាសម្រេចក្នុងរឿងក្តីការងាររបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ[31]។

ប៉ុន្តែ កាលបើសភាពាណិជ្ជកម្ម និងសភាការងារនៃសាលាជម្រះក្តីជាន់ខ្ពស់មិនអាចដំណើរបានដោយមូលហេតុខ្វះចៅក្រម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ គឺជាសមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់។ កិច្ចការទាំងនេះ ត្រូវចាត់ចែងដោយប្រធានសាលាជម្រះក្តីជាន់ខ្ពស់ដែលសភាជំនាញនោះស្ថិតនៅ។

ដោយឡែក កាលបើសភាជំនាញណាមួយខាងលើមានដំណើរការស្របទៅតាមច្បាប់ ស្តីពី"ការរៀបចំអង្គការតុលាការ"នេះ សភាជំនាញផ្សេងទៀតត្រូវផ្ទេររឿងក្តីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយមិនទាន់ចាត់ការទៅសភាជំនាញដែលមានសមត្ថកិច្ចវិញ[32]។

**១.២.១.៣.សមត្ថកិច្ច**

តុលាការកំពូលជាតុលាការជាន់ខ្ពស់ដែលមានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់[33]។ ដូច្នេះកាលណាមានបណ្តឹងប្តឹងមកតុលាការកំពូល នោះតុលាការកំពូលនឹងសម្រេចការបើកសវនាការជំនុំជម្រះតាមនីតិវិធីច្បាប់។ បណ្តឹងដែលប្តឹងមកតុលាការកំពូលអាចជា បណ្តឹងសាទុក្ខលើកទី១ បណ្តឹងសាទុក្ខលើកទី២ បណ្តឹងទាក់ទងនឹងសមត្ថកិច្ចតុលាការ បណ្តឹងសុំស្រូបទោស និងអាចជាបណ្តឹងសើរើ -ល-។

**ក-សភារួមក្រុម**

សភារួមក្រុមអាចត្រូវបង្កើតឱ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូលតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយកាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នានៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល។

សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់មានអំណាចបង្ខំឱ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម។ កាលបើសភារួមក្រុមត្រូវបង្កើតឱ្យមានឡើងសភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន)រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។ ប្រធានតុលាការ

[31] មាត្រា៦៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[32] មាត្រា៨៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[33] មាត្រា៦១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

កំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទអំពីច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា[34]។

### ខ-សភាពេញអង្គ

សភាពេញអង្គត្រូវបង្កើតឱ្យមានដំណើរការដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះលើ ៖

-លើបណ្តឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ស្របតាមនីតិវិធីជាធរមាន

-លើបណ្តឹងសើរើចំពោះសាលក្រម និងសាលដីកាស្ថាពរស្របតាមនីតិវិធីជាធរមាន។

សភាពេញអង្គក៏អាចត្រូវបង្កើតឱ្យមានដំណើរការផងដែរ ដើម្បីជំនុំជម្រះលើបណ្តឹងសើរើ ឬបណ្តឹងជំនុំជម្រះសាជាថ្មីក្នុងករណីដែលមានការស្នើសុំឱ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយ ពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល។ សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះដែលចេញសេចក្តីសម្រេចក្នុងនាមតុលាការកំពូល។ កាលបើសភាពេញអង្គត្រូវបង្កើតឱ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន)រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់របស់តុលាការកំពូល។ សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល[35]។

តុលាការកំពូលមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងសាទុក្ខលើកទី១ បណ្តឹងសាទុក្ខលើកទី២ បណ្តឹងសើរើ និងបណ្តឹងសុំស្រូបទោសផងដែរ។

តុលាការកំពូល គឺមានទិសដៅបន្តជម្រុញការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណីឱ្យបានត្រឹមត្រូវ ឆាប់រហ័ស និងបានច្រើន។ ជម្រុញឱ្យបន្តការផ្សព្វផ្សាយសាលដីការបស់តុលាការកំពូលឱ្យបានកាន់តែទូលំទូលាយតាមរយៈគេហទំព័ររបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ជាពិសេសចំពោះសាលដីកាថ្មីៗដើម្បីជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងជាព័ត៌មានពីសេចក្តីសម្រេចក្នុងការអនុវត្តច្បាប់ជូនដល់សាធារណៈជន។ បន្តកិច្ចការសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាតុលាការកំពូលនៃប្រទេសអាស៊ានក៏ដូចជាប្រទេសផ្សេងៗទៀតនៅក្នុងពិភពលោក។ បង្កើនសមត្ថភាពធនធានមនុស្សដែលមានស្រាប់ ដើម្បីឱ្យទាន់បរិបទសង្គមជាក់ស្តែង[36]។

---

[34] មាត្រា៦៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤ ដោយព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ដែលពាក់ព័ន្ធទៅនឹងការកំណត់សមត្ថកិច្ចរបស់សភានីមួយៗឱ្យបានច្បាស់លាស់នៅឡើយ ក្នុងរឿងពាណិជ្ជកម្ម រឿងការងារ ដូចនេះសភារួមក្រុមអាចត្រូវបង្កើតឱ្យមានដំណើរការ ដើម្បីចេញសេចក្តីសម្រេច អំពីសមត្ថកិច្ច និងវិវាទអំពីច្បាប់ ដែលមានដំណោះស្រាយខ្វែងគ្នា ដែលស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។

[35] មាត្រា៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[36] របាយការណ៍ សន្និបាត របស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ប្រចាំឆ្នាំ២០១៩

### ១. ២. ២. មហាអយ្យការអមតុលាការកំពូល

អង្គការអយ្យការជាស្ថាប័នដែលធ្វើការចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានាការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌព្រមទាំងធានាលើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន [37] ។ មុខងាររបស់អង្គការអយ្យការត្រូវបានកំណត់ជាគោលការណ៍ ដោយមាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"[38]។ តាមមាត្រានេះ អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា មានន័យថា មុខងារដ៏សំខាន់របស់អង្គការអយ្យការគឺ "ការអនុវត្តបណ្តឹងអាជ្ញា" តាមរយៈការចោទប្រកាន់ជនប្រព្រឹត្តល្មើសនឹងច្បាប់ដើម្បីឱ្យស្ថាប័នតុលាការវិនិច្ឆ័យ និងជំនុំជម្រះក្តី។ នៅក្នុងការអនុវត្តមុខងាររបស់ខ្លួនអង្គការអយ្យការត្រូវយោងទៅលើបទប្បញ្ញត្តិច្បាប់សារធាតុ និងបទប្បញ្ញត្តិច្បាប់នីតិវិធី ជាពិសេសគឺក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលជាច្បាប់នីតិវិធីគោលមួយសម្រាប់អង្គការអយ្យការ។ រីឯក្នុងរឿងក្តីរដ្ឋប្បវេណីវិញ ចាប់តាំងពីការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦មក អង្គការអយ្យការលែងដើរតួនាទីជាគូក្តីរណប ឬគូក្តីដើម តាមមាត្រា ៥ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាទៀតហើយ។ ក្រមនីតិវិធីរដ្ឋប្បវេណីគ្រាន់តែផ្តល់សិទ្ធិដល់តំណាងអយ្យការឱ្យចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់ប៉ុណ្ណោះ ប្រសិនបើតំណាងអយ្យការយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ។ មហាអយ្យការអមតុលាការកំពូលជាអង្គការអយ្យការជាន់ខ្ពស់ដែលនៅអមតុលាការកំពូល។

#### ១.២.២.១.សមាសភាព

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចជា **អគ្គព្រះរាជអាជ្ញា** ( អ្នកកាន់អាជ្ញាខ្ពស់ជាងព្រះរាជអាជ្ញា។ ចៅក្រមដែលជាប្រមុខនៃអយ្យការអមតុលាការជាន់ខ្ពស់។ ព្រះរាជអាជ្ញាដែលជាប្រមុខមហាអយ្យការ)។ **អគ្គព្រះរាជអាជ្ញារង** (បន្ទាប់ពីអគ្គព្រះរាជអាជ្ញា គឺអគ្គព្រះរាជអាជ្ញារង គេមិនហៅថាប្រធានមហាអយ្យការ ឬអនុប្រធានមហាអយ្យការទេ) **ព្រះរាជអាជ្ញា** (ចៅក្រមដែលបំពេញការងារខាងអយ្យការអមតុលាការ, ចៅក្រមជាម្ចាស់បណ្តឹងអាជ្ញាដែលមានសិទ្ធិចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ រួចបញ្ជូនទៅតុលាការ, មន្ត្រីតំណាងរបស់រដ្ឋនៅអមតុលាការជាន់ទាប ដូចជាតុលាការខេត្ត ក្រុង ឬសាលាដំបូង ឬតុលាការយោធា, អ្នកដែលមានសិទ្ធិចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌតាងនាមរដ្ឋាភិបាល ឬសង្គម)។ **ក្រឡាបញ្ជី** (មន្ត្រីតុលាការដែលបំពេញមុខងារធានានូវដំណើរការនៃលេខាធិការដ្ឋានរបស់យុត្តាធិការ)។ **មន្ត្រីរដ្ឋបាល** (ប្រសិនបើយើងញែកពាក្យថាមន្ត្រីហើយនឹងរដ្ឋបាលចេញពីគ្នានោះពាក្យថាមន្ត្រី មានន័យថា អ្នករាជការក្នុងក្របខណ្ឌមុខងារសាធារណៈទាំងឡាយនិងមន្ត្រីតុលាការមន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ រីឯពាក្យថារដ្ឋាបាលមានន័យថាការ

[37] មាត្រា២៧ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ២០០៧

[38] មាត្រា១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

គ្រប់គ្រងកិច្ចការផ្សេងៗមានលក្ខណៈជាឯកជន ឬជាសាធារណៈ) និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល[39]។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញាថ្នាក់ខ្ពស់បំផុត។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា[40]។

-អង្គការអយ្យការជាអង្គឯកភាព ដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូលត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

-អង្គការអយ្យការគឺជាអង្គអវិភាគ ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការសាលាជម្រះក្តីណាមួយមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបានតាមគោលការណ៍នេះ តំណាងអង្គការអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។

-អង្គការអយ្យការគឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ សាលាជម្រះក្តីនេះគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីក្នុងករណីដែល

---

[39] មាត្រា៦៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

**-អគ្គព្រះរាជអាជ្ញា** ដោយយោងតាម វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ១៧៧៨ បោះពុម្ពលើកទី៥ ឆ្នាំ២០១៨

**-អគ្គព្រះរាជអាជ្ញារង** ដោយយោងតាម វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ១៧៧៨ បោះពុម្ពលើកទី៥ ឆ្នាំ២០១៨

**-ព្រះរាជអាជ្ញា** ដោយយោងតាម វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ៩៧៥ បោះពុម្ពលើកទី៥ ឆ្នាំ២០១៨

**-ក្រឡាបញ្ជី** ដោយយោងតាម វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ១៧៣ បោះពុម្ពលើកទី៥ ឆ្នាំ២០១៨

**-មន្ត្រីរដ្ឋបាល** ដោយយោងតាម វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ១០៣៣/១១៥៣ បោះពុម្ពលើកទី៥ ឆ្នាំ២០១៨

[40] មាត្រា៩៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

ព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្ដីមិនត្រូវចុះក្នុងសេចក្ដីសម្រេចរបស់ខ្លួនយកការស្ដីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ ទាំងក្នុងរឿងក្ដីផ្សេងទៀត។ ប៉ុន្តែសាលាជម្រះក្ដីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញាអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន[41]។

### ១.២.២.២.សមត្ថកិច្ច

អង្គការអយ្យការអមតុលាការកំពូល មានមហាអយ្យការអមតុលាការកំពូលដែលត្រូវបានតំណាងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមអនុវត្តមុខងារនេះ ដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ក្នុងករណីមានធុរៈ ឬអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើជំនួសខ្លួនបាន ខណៈពេលដែលមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវចាត់តាំង បើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូលរហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ។

តួនាទីរបស់អយ្យការក្នុងក្របខណ្ឌនៃដំណើរការរឿងក្ដីព្រហ្មទណ្ឌ គឺជាភាគីនៅក្នុងរឿងក្ដី ជាបុគ្គលដែលតំណាងឱ្យសង្គមធ្វើបណ្ដឹងសុំឱ្យយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះផ្ដន្ទាទោសជនល្មើសតាមច្បាប់។ អង្គការអយ្យការមិនចូលរួមនៅក្នុងការសម្រេចសេចក្ដីទេ ប៉ុន្តែមានកាតព្វកិច្ចឃ្លាំមើល និងជម្រុញឱ្យមានការសម្រេចសេចក្ដីរបស់តុលាការឱ្យមានភាពច្បាស់លាស់ត្រឹមត្រូវ និងយុត្តិធម៌ក្លាយជាប្រយោជន៍ដល់សង្គម។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានតួនាទីចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់នៅពេលមានបណ្ដឹងសាទុក្ខ បណ្ដឹងសើរើ និងបណ្ដឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ[42]។

មហាអយ្យការអមតុលាការកំពូល គឺមានទិសដៅចូលរួមសវនាការដែលតុលាការកំពូលបានកំណត់។ ធ្វើសេចក្ដីសន្និដ្ឋាន ដែលតុលាការកំពូលបានបញ្ជូនមកឱ្យទាន់ពេលវេលា។ ជម្រុញឱ្យស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់អនុវត្តច្បាប់ដែលពាក់ព័ន្ធក្នុងវិស័យយុត្តាធិការឱ្យបានម៉ឺងម៉ាត់ខ្ជាប់ខ្ជួនស្របតាមឆន្ទៈច្បាប់។ បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្ដាមហាអយ្យការនៃប្រទេសអាស៊ានក៏ដូចជាប្រទេសផ្សេងៗទៀតក្នុងពិភពលោក

[41] មាត្រា៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៤

[42] មាត្រា៣២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

និងបន្តសិក្សាស្រាវជ្រាវបន្ថែម ដើម្បីបង្កើន និងពង្រឹងសមត្ថភាព និងបន្តការប្រជុំផ្ទៃក្នុងដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗឱ្យបានល្អ និងរីកចម្រើន[43]។

### ១. ២. ៣. អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

ទោះបីជាតុលាការកំពូលមានមុខងារដ៏សំខាន់ដែលជាអ្នកសម្រេចសេចក្តី និងជំនុំជម្រះទៅលើរឿងក្តីក៏ពិតមែន ប៉ុន្តែមុខងារដ៏សំខាន់នេះដើម្បីឱ្យមានភាពរលូន និងមានប្រសិទ្ធភាពទាក់ទងការប្រព្រឹត្តទៅរបស់ស្ថាប័នតុលាការកំពូល អាស្រ័យមានការរៀបចំរដ្ឋបាលការងាររបស់តុលាការកំពូលទាំងមូល។ ការងាររដ្ឋបាលទាំងនេះគឺជាមុខងាររដ្ឋបាលដ៏សំខាន់មួយរបស់តុលាការកំពូលដែលជាជំនួយមិនអាចខ្វះបានសម្រាប់ដំណើរការជំនុំជម្រះរឿងក្តីស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ និងដើម្បីឱ្យប្រជាពលរដ្ឋមានជំនឿទុកចិត្តលើតុលាការ។ រដ្ឋបាលតុលាការនៅត្រង់ផ្នែកនេះ សំដៅទៅលើការគ្រប់គ្រងជាទូទៅនៅក្នុងតុលាការកំពូលដែលមិនពាក់ព័ន្ធនឹងការគ្រប់គ្រងរឿងក្តីតាមនីតិវិធីទេ តែសំដៅទៅលើការគ្រប់គ្រងមន្ត្រីបុគ្គលិក ការគ្រប់គ្រងចាត់ចែងថវិកា និងទំនាក់ទំនងរដ្ឋបាលជាមួយនឹងស្ថាប័នដទៃទៀត។ នៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មានអង្គភាពរដ្ឋបាលមួយដែលស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។ អង្គភាពរដ្ឋបាលនៃតុលាការកំពូល ហៅថាអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដែលមានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន[44]។

បន្ថែមពីនេះទៀតថ្វីត្បិតតែតុលាការកំពូលស្ថិតនៅក្នុងអំណាចតុលាការ ដែលជាអំណាចឯករាជ្យពីអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ តែការសហការ និងទំនាក់ទំនងក្នុងភារកិច្ចតែងតែមានជៀសមិនរួចជាសត្យានុម័ត។ បច្ចុប្បន្នការងាររដ្ឋបាលនេះ ត្រូវទទួលបន្ទុកដោយអគ្គលេខាធិការដ្ឋាននៃតុលាការកំពូល[45]។ អគ្គលេខាធិការដ្ឋានអនុវត្តការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលប្រគល់ឱ្យ ព្រមទាំងការងារនៃការទំនាក់ទំនងជាមួយនឹងស្ថាប័នផ្សេងៗទៀតដើម្បីសម្របសម្រួលការងារសម្រេចសេចក្តី និងជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាព និងមានជំនឿទុកចិត្តពីប្រជាពលរដ្ឋ ។

#### ១.២.៣.១.សមាសភាព

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការ

[43] របាយការណ៍ សន្និបាត របស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ប្រចាំឆ្នាំ២០១៩

[44] មាត្រា១០ កថាខណ្ឌទី១ និងកថាខណ្ឌទី៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

អមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋានត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធាន ការិយាល័យរដ្ឋបាល ឬត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ ហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ។ មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌[46]។

### ១.២.៣.២.មុខងារ

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឱ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពុលលើះ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ, ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ, ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច, រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, ការងារទំនាក់ទំនងសាធារណៈ, ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់, រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌, ការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលប្រគល់ឱ្យ, អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត។ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋានដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[47]។

អគ្គលេខាធិការដ្ឋាន គឺមានទិសដៅរៀបចំថវិកាកម្មវិធីឱ្យបានសមស្របដើម្បីគាំទ្រដល់ដំណើរការការងាររបស់តុលាការកំពូល និងមហាអយ្យការអមតយលាការកំពូល។ កែសម្រួលនីតិវិធីនៃការគ្រប់គ្រង

[46] មាត្រា៧២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

[47] មាត្រា៧១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ២០១៤

ទិន្នន័យរឿងក្តី, ការចេញសាលដីកា ការប្រមូល និងការបញ្ជូនសាលដីកាឱ្យបានឆាប់រហ័សទៅតាមគោលដៅដែលត្រូវទទួល។ កែលំអរបៀបរបបការងាររបស់អគ្គលេខាធិការដ្ឋានកុំឱ្យកើតមានបញ្ហាដូចមានលើកឡើងក្នុងបញ្ហាប្រឈមខាងលើ។ បន្តពង្រឹងតួនាទីភារកិច្ចរបស់នាយកដ្ឋាននីមួយៗឱ្យស្របតាមអនុក្រឹត្យលេខ ២៣ អនក្រ.បកចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល និងសេចក្តីសម្រេចលេខ២២៤/១៦ តកក.សសរ ចុះថ្ងៃទី២២ ខែមិថុនាឆ្នាំ២០១៦ របស់ប្រធានតុលាការកំពូលស្តីពីការបែងចែកភារកិច្ច និងការទទួលខុសត្រូវនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឱ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលដែលមានរចនាសម្ព័ន្ធ ដូចជានាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក, នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ, នាយកដ្ឋានកិច្ចការតុលាការ និងនាយកដ្ឋានកិច្ចការមហាអយ្យការ។

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។ នាយកដ្ឋាននីមួយៗត្រូវបែងចែកជាការិយាល័យ។ ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។ នាយកដ្ឋាន និងការិយាល័យនីមួយៗនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលថ្នាក់ស្មើនឹងនាយកដ្ឋាន និងការិយាល័យថ្នាក់កណ្តាល[48]។

**ក-នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក**

នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិកជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងាររដ្ឋបាលទូទៅ រដ្ឋបាលសំណុំរឿង បុគ្គលិក បណ្ណការ និងបូកសរុប។ ដោយឡែកនាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិកក៏មានការិយាល័យចំណុះខ្លួនចំនួន ០៣ ការិយាល័យ ដូចខាងក្រោម៖

-ការិយាល័យរដ្ឋបាលទូទៅ

-ការិយាល័យកិច្ចការបុគ្គលិក

-ការិយាល័យទំនាក់ទំនងសាធារណៈ

ការិយាល័យនីមួយៗទទួលបន្ទុកកិច្ចការ និងចាត់ចែងផ្សេងៗគ្នាដោយការិយាល័យរដ្ឋបាលទូទៅទទួល និងចាត់ចែងឯកសារចេញ-ចូលរបស់តុលាការកំពូលមហាអយ្យការអមតុលាការកំពូលនិងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការរៀបចំ និងសម្របសម្រួលការងាររដ្ឋបាលទូទៅគ្រប់គ្រងសៀវភៅចុះលេខលិខិតចេញ-ចូល និងរក្សាទុកឯកសារគ្រប់គ្រងសៀវភៅ និងប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿងក្តី និងរៀបចំបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ គ្រប់គ្រងសំណុំរឿងដែលចាត់ការរួច ទិន្នន័យ, សាលដីកា, និងព្រឹត្តិបត្រ រៀបចំគ្រប់គ្រងគេហទំព័រ និង

[48] មាត្រា៥ នៃអនុក្រឹត្យ លេខ២៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

បណ្តាញទំនាក់ទំនងសង្គមផ្សេងៗដើម្បីលើកកម្ពស់ការទទួលព័ត៌មានរបស់សាធារណជន ចរាចរលិខិត និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលចាត់ចែងសម្របសម្រួល និងសហការបញ្ជូនសាលដីកា និងសេចក្តីសម្រេចនានាជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗតាមច្បាប់កំណត់គ្រប់គ្រងត្រារបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលគណនាកំណត់ចំនួនប្រាក់ពន្ធដាក់ពាក្យសុំ និងប្រាក់ផ្សេងទៀតតាមច្បាប់កំណត់សម្របសម្រួលរៀបចំកម្មវិធីសវនាការ និងកិច្ចការរដ្ឋបាលទូទៅនៃសវនាការ តម្កល់ឯកសាររឿងក្តីសំណៅដើម និងថតចម្លងឯកសាររឿងក្តីជូនអង្គភាពពាក់ព័ន្ធ សម្របសម្រួលសេវាបកប្រែ និងសេវាផ្សេងៗធានាប្រសិទ្ធិភាពនៃសុវត្ថិភាពរដ្ឋបាលរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល រៀបចំគ្រប់គ្រង សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំ របស់ការិយាល័យ និងនាយកដ្ឋាន រៀបចំរបាយការណ៍សកម្មភាពប្រចាំខែត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំរបស់តុលាការកំពូល មហាអយ្យការអមតុលាការកំពូល និងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

ដោយឡែក ការិយាល័យកិច្ចការបុគ្គលិក និងការិយាល័យទំនាក់ទំនងសាធារណៈ និងបណ្ណការទទួលបន្ទុកមួយចំនួន ដូចជាគ្រប់គ្រង និងសម្របសម្រួលរាល់ការងារបុគ្គលិកដោយធ្វើទំនាក់ទំនងជាមួយក្រសួងយុត្តិធម៌ រីឯការិយាល័យទំនាក់ទំនងសាធារណៈ និងបណ្ណការ សម្របសម្រួល និងទំនាក់ទំនងរាល់បណ្តាប្រទេសនានានៅលើវិស័យតុលាការ រៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈ និងកិច្ចព្រមព្រៀងជាមួយប្រទេសនានា និងអង្គការអន្តរជាតិ ដោយសហការជាមួយនឹងក្រសួងយុត្តិធម៌ ចាត់ចែង និងសម្របសម្រួលការបញ្ជូនសាលដីកា និងសេចក្តីសម្រេចនានាជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នដែលពាក់ព័ន្ធតាមកំណត់ច្បាប់។ ម៉្យាងទៀត ការិយាល័យទាំង ០៣នេះ ត្រូវអនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ[49]។

**ខ-នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ**

នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងារផែនការថវិកា គណនេយ្យ បេឡា លទ្ធកម្ម និងសារពើភ័ណ្ឌទាំងឡាយ។

នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុក៏មានការិយាល័យចំណុះចំនួន ០៣ ការិយាល័យ ដូចខាងក្រោម៖

-ការិយាល័យផែនការ

-ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ការិយាល័យលទ្ធកម្ម

[49]មាត្រា៦ នៃអនុក្រឹត្យ លេខ២៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

ការិយាល័យនីមួយៗទទួលបន្ទុកកិច្ចការ និងចាត់ចែងផ្សេងៗគ្នាដោយការិយាល័យផែនការទទួលចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន រៀបចំផែនការថវិការបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការ បូកសរុបផែនការសកម្មភាព និងផែនការថវិកាពីគ្រប់នាយកដ្ឋានដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។

រីឯការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គងទទួលបន្ទុករៀបចំគ្រប់គ្រងបេឡារាល់ចំណូល-ចំណាយរៀបចំគ្រប់គ្រងបែងចែកតាមតម្រូវការនូវសម្ភារៈបរិក្ខារបច្ចេកទេសដែលបានស្នើសុំនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។

ចំណែកឯ ការិយាល័យលទ្ធកម្មវិញទទួលបន្ទុកទៅលើការរៀបចំ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ។ រៀបចំបែបបទ និងគ្រប់គ្រងនីតិវិធីលទ្ធកម្មសាធារណៈតាមនីតិវិធីជាធរមាន អនុវត្ត និងប្រតិបត្តិកិច្ចលទ្ធកម្មសាធារណៈតាមគោលការណ៍ណែនាំ និងនីតិវិធីជាធរមាន លើសពីនេះត្រូវទទួលខុសត្រូវ និងត្រួតពិត្យនីតិវិធីលទ្ធកម្មសាធារណៈផងដែរ[50]។

ការិយាល័យទាំង ០៣ ដែលនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុត្រូវអនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

**គ-នាយកដ្ឋានកិច្ចការតុលាការ**

នាយកដ្ឋានកិច្ចការតុលាការ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការលើការងារសម្របសម្រួល ចាត់ចែងបន្តសំណុំរឿង ព្រមទាំងការងារផ្សេងទៀតដែលជាសមត្ថកិច្ចរបស់តុលាការកំពូល។

នាយកដ្ឋានកិច្ចការតុលាការក៏មានការិយាល័យចំណុះចំនួន ០៣ ការិយាល័យ ដូចខាងក្រោម៖

-ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការតុលាការ

-ការិយាល័យទំនាក់ទំនងតុលាការ

-ការិយាល័យព័ត៌មានវិទ្យា

ការិយាល័យនីមួយៗទទួលបន្ទុកកិច្ចការ និងចាត់ចែងផ្សេងៗគ្នាសម្រាប់ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការតុលាការទទួលបន្ទុកទទួល និងចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន ចរាចរលិខិត និងបញ្ជូនទៅសភាជំនាញនីមួយៗ ព្រមទាំងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល បញ្ជូនលទ្ធផលចំណាត់ការរឿងក្តី ឬបញ្ចូលលទ្ធផលនៃចំណាត់ការទៅក្នុងប្រព័ន្ធទិន្នន័យ សម្របសម្រួលរៀបចំកម្មវិធីជំនុំជម្រះរឿងក្តីអាទិភាព និងរឿងក្តីធម្មតា ស្រាវជ្រាវ និងចងក្រងសាល

[50] មាត្រា៧ នៃអនុក្រឹត្យ លេខ២៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

ដីកាសេចក្តីសម្រេចនានារបស់តុលាការកំពូល ចងក្រងឯកសារច្បាប់ និងសេចក្តីពន្យល់ផ្សេងៗក្នុងវិស័យតុលាការ។

ការិយាល័យទំនាក់ទំនងតុលាការទទួលបន្ទុកសម្របសម្រួលការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល បញ្ជូនសាលដីកា ឬសេចក្តីសម្រេចនានាទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតតាមច្បាប់កំណត់ ទំនាក់ទំនងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្តី សម្របសម្រួលទំនាក់ទំនងរវាងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល សម្របសម្រួលការបញ្ជូនសំណុំរឿងក្តីពីសភាជំនាញត្រឡប់ទៅសាលាជម្រះក្តីមានសមត្ថកិច្ចស្របតាមនីតិវិធីជាធរមានប្រមូល និងចងក្រងសាលដីកាស្ថាពរ និងរូបមន្តអនុវត្ត។

ការិយាល័យព័ត៌មានវិទ្យាទទួលបន្ទុករៀបចំបង្កើតពង្រឹង និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ដោយសហការជាមួយក្រសួងយុត្តិធម៌ដើម្បីទ្រទ្រង់អភិវឌ្ឍន៍ប្រព័ន្ធតុលាការឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព[51]។

ការិយាល័យទាំង ០៣ ដែលនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានកិច្ចការតុលាការ ត្រូវអនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

**ឃ-នាយកដ្ឋានកិច្ចការមហាអយ្យការ**

នាយកដ្ឋានកិច្ចការមហាអយ្យការ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការ លើការងារសម្របសម្រួល ចាត់ចែងបន្តសំណុំរឿង និងការងារទាំងឡាយ ដែលជាសមត្ថកិច្ចរបស់មហាអយ្យការអមតុលាការកំពូល។

នាយកដ្ឋានកិច្ចការមហាអយ្យការ ក៏មានការិយាល័យចំណុះចំនួន ០៣ ការិយាល័យដូចខាងក្រោមៈ

-ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការមហាអយ្យការ

-ការិយាល័យទំនាក់ទំនងមហាអយ្យការ

-ការិយាល័យបច្ចេកទេសព្រហ្មទណ្ឌ

ការិយាល័យនីមួយៗទទួលបន្ទុកកិច្ចការ និងចាត់ចែងផ្សេងៗគ្នា ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការមហាអយ្យការ ទទួលបន្ទុក ទទួល ចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន ចាត់ចែងបន្តសំណុំរឿង និងបណ្តឹងផ្សេងៗដែលចូលមកមហាអយ្យការ ចូលរួមរក្សា និងតម្កល់ឯកសាររឿង ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង។

[51] មាត្រា៨ នៃអនុក្រឹត្យ លេខ២៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

ការិយាល័យទំនាក់ទំនងមហាអយ្យការ ទទួលបន្ទុក គ្រប់គ្រងសៀវភៅ និងប្រព័ន្ធទិន្នន័យចុះបញ្ជីរឿងព្រហ្មទណ្ឌ ទំនាក់ទំនងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលាមន្ត្រីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្ដី សម្របសម្រួលទំនាក់ទំនងរវាងមហាអយ្យការអមតុលាការ និងតុលាការចូលរួមរក្សា និងតម្កល់ឯកសាររឿងក្ដី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានអំពីចំណាត់ការបណ្ដឹង និងដំណើរការនីតិវិធីសំណុំរឿងក្ដី។

ការិយាល័យបច្ចេកទេសព្រហ្មទណ្ឌទទួលបន្ទុករៀបចំ និងសម្របសម្រួលការងារបច្ចេកទេសទាក់ទងនឹងដំណើរការរឿងក្ដីព្រហ្មទណ្ឌ រៀបចំបញ្ជូនសាលដីកាស្ដាពរទៅសាលាជម្រះក្ដី អយ្យការ និង/ឬ ពន្ធនាគារដែលមានសមត្ថកិច្ច សម្របសម្រួលជាមួយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ អ្នកជំនាញការ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្ដីព្រហ្មទណ្ឌ[52]។

ការិយាល័យទាំង ០៣ ដែលនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានកិច្ចការមហាអយ្យការត្រូវអនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការកែសម្រួល និងបង្កើតការិយាល័យ ឬអង្គភាពមួយចំនួនចំណុះឱ្យអង្គលេខាធិការដ្ឋានរដ្ឋបាលតុលាការបាន។

[52] មាត្រា៩ នៃអនុក្រឹត្យ លេខ២៣ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

# ជំពូកទី២
# នីតិវិធីនៃបណ្តឹងសារទុក្ខ

# ជំពូកទី២
# នីតិវិធីនៃបណ្តឹងសាទុក្ខ

## ២. ១. សញ្ញាណនៃបណ្តឹងសាទុក្ខ

### ២. ១. ១. អំពីបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខសំដៅទៅលើបណ្តឹងឧបាស្រ័យ[53] ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍មកកាន់តុលាការកំពូល ដោយធ្វើឡើងដោយអ្នកមានសិទ្ធិអាចធ្វើបណ្តឹងសាទុក្ខ ហើយត្រូវបានពិនិត្យមើលភាពត្រឹមត្រូវរបស់បណ្តឹងសាទុក្ខដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល។ បណ្តឹងសាទុក្ខទៅតុលាការកំពូលមានសារៈសំខាន់វាគឺជាដំណាក់កាលចុងក្រោយហើយបិទផ្លូវតវ៉ាប្រសិនបើបណ្តឹងសាទុក្ខត្រូវបានតុលាការបដិសេធ នោះនាំឱ្យសេចក្តីសម្រេចដែលតវ៉ានោះមានអាជ្ញាអស់ជំនុំ ហើយអ្នកប្តឹងសាទុក្ខគឺមិនអាចប្តឹងសាទុក្ខជាថ្មីម្តងទៀតនោះទេ។ នៅពេលដែលបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងនោះ សភាព្រហ្មទណ្ឌនៃតុលាការកំពូលត្រូវពិនិត្យទៅលើពាក្យបណ្តឹងសាទុក្ខថាត្រឹមត្រូវតាមនីតិវិធីនៃបណ្តឹងសាទុក្ខដែរឬទេ។ ចំពោះសាលដីកានៃសភាស៊ើបសួររបស់សាលាឧទ្ធរណ៍ រឿងបត្យាប័ន ព្រមទាំងសាលដីកាចុងក្រោយដែលសម្រេចដោយសាលាឧទ្ធរណ៍ ក៏អាចត្រូវប្តឹងសាទុក្ខបានដែរ។ ប៉ុន្តែ វិធីតវ៉ានេះមិនអាចធ្វើបានទេចំពោះសាលដីកានៃសភាស៊ើបសួរដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះនោះ[54]។ បណ្តឹងសាទុក្ខអាចនឹងត្រូវបដិសេធចោលក្នុងករណីដែលបណ្តឹងសាទុក្ខនោះផ្ទុយទៅនឹងច្បាប់ ឬក៏ក្នុងករណីដែរបណ្តឹងសាទុក្ខនោះមិនមានមូលហេតុត្រឹមត្រូវស្របទៅតាមច្បាប់ដែលកំណត់។ នៅពេលដែលបណ្តឹងសាទុក្ខត្រូវបានបដិសេធ តុលាការត្រូវចេញសេចក្តីសម្រេចអំពីការបដិសេធនូវបណ្តឹងសាទុក្ខ ដោយមានសំអាងហេតុដែលជាមូលហេតុនៃការបដិសេធនោះ។

នៅមុនពេលដែលពាក្យបណ្តឹងសាទុក្ខត្រូវបានបញ្ជូនមកតុលាការកំពូល ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿង ហើយបញ្ជូនមកកាន់តុលាការកំពូលក្នុងរយៈពេលដ៏ខ្លីបំផុតបន្ទាប់ពីពាក្យបណ្តឹងសាទុក្ខត្រូវបានប្តឹងដោយអ្នកប្តឹងសាទុក្ខ។

### ២. ១. ២. ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ[55]។

---

[53] បណ្តឹងឧបាស្រ័យ (បណ្តឹងតវ៉ារបស់ភាគីដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ(សាលក្រម សាលដីកា ដីកាសម្រេច) របស់ចៅក្រម ឬតុលាការ ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។ (វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ៦៦៧

[54] មាត្រា៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[55] មាត្រា៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿងហើយបញ្ជូនសំណុំរឿងទៅក្រឡាញ្ជីតុលាការកំពូលក្នុងរយៈពេលដ៏ខ្លីបំផុត មាត្រា៤២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[56]។

តាមមាត្រា៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខបានមានៈ

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ជនជាប់ចោទ ឬពិរុទ្ធជន

-បុគ្គលដែលត្រូវគេទាមទារក្នុងករណីនីតិវិធីបត្យាប័ន

-ដើមបណ្តឹងរដ្ឋប្បវេណី

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងសាទុក្ខត្រូវធ្វើក្នុងរយៈពេល ០១ខែ ចំពោះសាលដីរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងមាត្រានេះផងដែរ ក៏បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីការចាប់ផ្តើមរាប់រយៈពេលនៃការធ្វើបណ្តឹងសាទុក្ខនេះ។ រយៈពេល ០១ខែ ត្រូវគិតពីការប្រកាសសាលដីកាបើជាសាលដីកាចំពោះ ឬគិតពីការឱ្យដំណឹងបើជាសាលដីកាដែលចាត់ទុកថាជាចំពោះមុខ ឬផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់ កាលបើជាសាលដីកាកំបាំងមុខ។

ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័ន [57] អាចតំណាងដោយមេធាវី។ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ។ ប៉ុន្តែជនជាប់ចោទ ឬពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ[58]។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ[59]។

### ២. ១. ៣. អានុភាពបន្ទាប់នៃបណ្តឹងសាទុក្ខ

ស្ថិតនៅក្នុងដំណាក់កាលនៃរយៈពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខ ការអនុវត្តសេចក្តីសម្រេចរបស់សាលា

[56] មាត្រា៤២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] សូមអាន កថាភាគទី៣ "នីតិវិធីនៃបត្យាប័ន" នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] បត្យាប័ន គឺជានីតិវិធីនៃការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយទៀត ដើម្បីយកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះមកអនុវត្តទោសនៅក្នុងប្រទេសខ្លួន។

[59] មាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧទ្ធរណ៍ត្រូវបានបង្អង់សិន មានន័យថាការអនុវត្តនូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលត្រូវបានតវ៉ានេះត្រូវតែបង្អង់ក្នុងខណៈពេលដែលតុលាការកំពូលនៅមិនទាន់បានសម្រេចសេចក្តី។ ដូចនេះការអនុវត្តសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ត្រូវបានបង្អង់ក្នុងរយៈពេលប្តឹងសាទុក្ខហើយបើសិនមានបណ្តឹងសាទុក្ខនៅក្នុងរយៈពេលធ្វើបណ្តឹងសាទុក្ខការអនុវត្តការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ត្រូវបង្អង់រហូតដល់ពេលដែលតុលាការកំពូលចេញនូវសេចក្តីសម្រេច។

ថ្វីត្បិតតែ បណ្តឹងសាទុក្ខមានអានុភាពបង្អង់នូវការអនុវត្តសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក៏ពិតមែន ប៉ុន្តែការអនុវត្តពន្ធនាគារ គឺមិនត្រូវបានបង្អង់ឡើយក្នុងករណីដែលជនជាប់ចោទបានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍ក្នុងនាមខ្លួនជាជនជាប់ឃុំ។

ម្យ៉ាងវិញទៀត អានុភាពនៃការបង្អង់របស់បណ្តឹងសាទុក្ខនេះមិនអាចបង្អង់ចំពោះដីកាបង្គាប់ឱ្យចាប់ខ្លួនបានទេ មានន័យថាដីកាបង្គាប់ឱ្យចាប់ខ្លួននេះនៅតែមានអានុភាពដដែល ហើយការឃុំខ្លួនបណ្តោះអាសន្ននៅតែមានអានុភាពអនុវត្តបន្ត ក៏ដូចជាករណីបុគ្គលដែលជាប់ឃុំក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័នក៏នៅតែជាប់ឃុំដដែល។ ប៉ុន្តែក្នុងករណីដែលមានការសម្រេចសេចក្តីឱ្យជនជាប់ចោទរួចខ្លួននោះ ជនជាប់ចោទនោះត្រូវបានដោះលែងឱ្យមានសេរីភាព[60]។

## ២. ២. លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ

### ២. ២. ១. មូលហេតុនៃបណ្តឹងសាទុក្ខ

ការធ្វើបណ្តឹងសាទុក្ខត្រូវមានមូលហេតុដូចបានរៀបរាប់នៅ មាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ និយាយម្យ៉ាងទៀតថា តុលាការកំពូលអាចបដិសេធនូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បានក្នុងករណីបណ្តឹងសាទុក្ខ[61]មានមូលហេតុដូចជា៖

**ក. សមាសភាពមិនស្របច្បាប់នៃតុលាការ**

សមាសភាពនេះសំដៅទៅលើសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះរបស់តុលាការជាន់ក្រោម។

-កាលណាសាលាដំបូង ឬសាលាឧទ្ធរណ៍ជំនុំជម្រះរឿងក្តីដោយមានសមាសភាពមិនស្របទៅតាមលក្ខខណ្ឌដែលច្បាប់បានតម្រូវទេ នោះវាជាមូលហេតុដែលនាំឱ្យតុលាការកំពូលបដិសេធបណ្តឹងសាទុក្ខនោះ។

-ការបដិសេធដោយតុលាការកំពូលទៅលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ហើយបង្វិលទៅឱ្យសាលាឧទ្ធរណ៍សម្រេចសេចក្តីសាជាថ្មីឡើងវិញ ហើយសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះសាជាថ្មីនេះគឺត្រូវផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាថ្មីផ្សេងពីមុន[62]។ ក្នុងករណីនេះប្រសិនបើសាលាឧទ្ធរណ៍មិនបានផ្លាស់ប្តូរសមាស

[60] មាត្រា ៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[61] មាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[62] មាត្រា៤៣៩ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ភាពក្រុមប្រឹក្សាថ្មីទេ នោះនឹងនាំឱ្យសមាសភាពក្រុមប្រឹក្សាជំនុំជម្រះនេះមានភាពផ្ទុយនឹងច្បាប់ដែលនេះជាមូលហេតុ នាំឱ្យតុលាការកំពូលបដិសេធបណ្ដឹងសាទុក្ខដែលប្ដឹងទៅលើសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍បាន។

-ការជំនុំជម្រះនូវបទឧក្រិដ្ឋនៅសាលាដំបូង ច្បាប់តម្រូវឱ្យមានសមាសភាពចៅក្រមបីរូប តែប្រសិនបើសាលាដំបូងជំនុំជម្រះនូវបទឧក្រិដ្ឋនោះមានសមាសភាពចៅក្រមមួយរូបទៅវិញ នោះនាំឱ្យការជំនុំជម្រះនេះមានភាពមិនស្របច្បាប់នៃតុលាការ។ ក្នុងករណីនេះ ប្រសិនបើសាលាឧទ្ធរណ៍ពុំបានពិនិត្យលើចំណុចនេះទេ នោះអ្នកមានសិទ្ធិអាចប្ដឹងសាទុក្ខអាចលើកពីបញ្ហានេះនៅក្នុងបណ្ដឹងសាទុក្ខដើម្បីឱ្យតុលាការកំពូលធ្វើការបដិសេធលើសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍បាន ប៉ុន្តែបើទោះបីជាករណីនេះអ្នកប្ដឹងសាទុក្ខមិនបានលើកឡើងក្នុងបណ្ដឹងសាទុក្ខក៏ដោយ ក៏តុលាការកំពូលអាចលើករឿងនេះមកធ្វើការបដិសេធបណ្ដឹងសាទុក្ខដោយឆន្ទានុសិទ្ធិបានដែរ។

-ករណីមិនព្រមវៀរចាកដែលនាំឱ្យមានការមោឃភាពចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ ការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ[63]។ ករណីនេះ ប្រសិនចៅក្រមស៊ើបសួរចូលរួមក្នុងការជំនុំជម្រះ នោះបណ្ដឹងសាទុក្ខក៏អាចត្រូវបានបដិសេធដោយតុលាការកំពូលផងដែរ។

ការបកស្រាយអំពីសមាសភាពនៃតុលាការនេះ គឺចង់សំដៅទៅលើវិសមិតភាពនៃតុលាការ។ មាត្រា ៧៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការបានចែងថា "មុខងារធ្វើបណ្ដឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះត្រូវបែងចែកដាក់ពីគ្នា។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្ដីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្ដីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ"[64]។ ដោយសារតែបែបនេះហើយទើបសមាសភាពមិនស្របច្បាប់នៃតុលាការអាចជាមូលហេតុដែលនាំឱ្យតុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម។

### ខ. អសមត្ថកិច្ចនៃតុលាការ

អសមត្ថកិច្ចនៃតុលាការនៅក្នុងន័យនេះ គឺសំដៅទៅលើសមត្ថកិច្ចដែនដី និងសមត្ថកិច្ចសម្ភារៈ។

កាលណាតុលាការថ្នាក់ក្រោមជំនុំជម្រះនូវរឿងក្ដីដែលមិនមែនជាសមត្ថកិច្ចរបស់ខ្លួនទេនោះ តុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍បាន ដោយសំអាងហេតុថាអសមត្ថកិច្ចនៃតុលាការ។

### គ. ការរំលោភអំណាច

តុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ដែលសម្រេចដោយរំលោភអំណាច

[63] មាត្រា៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[64] មាត្រា៧៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ នស/រកម/០៧១៤/០១៥ ឆ្នាំ ២០១៤

បាន។ ការរំលោភអំណាចកើតមាននៅពេលដែលតុលាការអនុវត្តអំណាចរបស់ខ្លួនលើសពីច្បាប់បានកំណត់ ឬការសម្រេចសេចក្តីដោយរំលោភអំណាចដែលច្បាប់ប្រគល់ឱ្យ*(ការសម្រេចសេចក្តីហួសភារៈកិច្ចរបស់ខ្លួន)*។

*ជាឧទាហរណ៍៖ ករណីរឿងមុនអង្គសេចក្តីដែលពាក់ព័ន្ធនឹងការសម្រេចឃុំខ្លួន ឬនៅក្រៅឃុំតុលាការដែលទទួលបណ្តឹងឧបាស្រ័យពីការសម្រេចនេះ គឺមិនអាចសម្រេចសេចក្តីទៅលើអង្គសេចក្តីបានឡើយ ព្រោះតុលាការថ្នាក់ក្រោមនៅពុំទាន់សម្រេចសេចក្តីដល់អង្គសេចក្តីនៅឡើយទេ ដូច្នេះតុលាការដែលទទួលបណ្តឹងឧបាស្រ័យត្រូវសម្រេចសេចក្តីតែទៅលើរឿងមុនអង្គសេចក្តីដែលត្រូវបានប្តឹងតែប៉ុណ្ណោះ។ ក្នុងករណីនេះ ប្រសិនបើសាលាឧទ្ធរណ៍បានសម្រេចសេចក្តីទៅលើអង្គសេចក្តីនោះ តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយសារមូលហេតុនៃការរំលោភអំណាច។*

**ឃ. ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់**

សេចក្តីសម្រេចតុលាការថ្នាក់ក្រោមត្រូវបានបដិសេធដោយតុលាការកំពូលដោយមូលហេតុសេចក្តីសម្រេចទាំងនោះធ្វើឡើងដោយបំពានច្បាប់ ឬអនុវត្តខុសច្បាប់។ នៅពេលដែលសាលាឧទ្ធរណ៍ចេញសេចក្តីសម្រេចបង្គាប់ឱ្យមានការអនុវត្តភ្លាមៗនូវខ្លឹមសារនៃសេចក្តីសម្រេចរបស់ខ្លួន បើទោះបីជាច្បាប់មានចែងផ្សេងពីនេះថា ការប្តឹងសាទុក្ខមានអានុភាពផ្អាកនូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ក៏ដោយ។

*ជាឧទាហរណ៍៖ ការស្ថិតនៅក្នុងរយៈពេលនៃបណ្តឹងសាទុក្ខមកកាន់តុលាការកំពូលនោះ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ត្រូវបានផ្អាកការអនុវត្ត រហូតដល់ពេលដែលតុលាការកំពូលចេញសេចក្តីសម្រេច ប៉ុន្តែសាលាឧទ្ធរណ៍បែរជាអនុវត្តនូវសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលនៃបណ្តឹងសាទុក្ខនោះ។*

ម្យ៉ាងវិញទៀត ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ នៅពេលដែលច្បាប់ចែងឱ្យដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅក្នុងលក្ខខណ្ឌដូចជា ជនជាប់ចោទមានការងារធ្វើ មានគ្រួសារមានទីលំនៅពិតប្រាកដជាអាទិ៍។ *ឧទាហរណ៍៖ តុលាការកំពូលយល់ឃើញថា នៅខណៈពេលដែលជនជាប់ចោទពុំមានទីលំនៅអចិន្ត្រៃយ៍ និងពិតប្រាកដនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទេ ហើយក៏ពុំមានទ្រព្យសម្បត្តិ ឬប្រាក់កាសសម្រាប់ធានាសំណងដល់ជនរងគ្រោះ ដើម្បីសុំនៅក្រៅឃុំដែលជាក់ស្តែងពេលដែល សាលាឧទ្ធរណ៍សម្រេចឱ្យជននេះនៅក្រៅឃុំ ជននេះបានគេចខ្លួន និងពុំបានមកចូលរួមសវនាការនេះទេ។* ដូច្នេះការដែលសាលាឧទ្ធរណ៍សម្រេចឱ្យជនជាប់ចោទនោះ ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន គឺជាការរំលោភលើលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ ព្រមទាំងពុំបានសម្រេចឱ្យជនត្រូវចោទ ឬជនជាប់ចោទដាក់ប្រាក់ធានាដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានទំនុកចិត្តពេលដែលសេចក្តីសម្រេចចូលជាស្ថាពរ ត្រង់ចំណុចនេះតុលាការកំពូលអាចបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយមូលហេតុការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់។

**ង. ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តថាត្រូវទុកជាមោឃៈ**

កាលណាសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមធ្វើឡើងដោយបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បានបញ្ញត្តថាត្រូវទុកជាមោឃៈ តុលាការអាចនឹងបដិសេធចោលសេចក្តីសម្រេចទាំងនោះ។ ករណីមួយចំនួនដែលច្បាប់កំណត់ថាមានមោឃភាព ឬវិសមិតភាពរវាងមុខងារនៃបណ្តឹងអាជ្ញា មុខងារស៊ើបសួរ ឬក៏មុខងារជំនុំជម្រះនោះ ចៅក្រមដែលទទួលភារកិច្ចស៊ើបសួរក្នុងរឿងក្តីមួយ គឺមិនអាចទទួលភារកិច្ចមកជំនុំជម្រះក្នុងរឿងក្តីដដែលនោះបានទេ *(មានវិសមិតភាព)*។ ហេតុដូច្នេះ សេចក្តីសម្រេចទាំងឡាយរបស់តុលាការថ្នាក់ក្រោមដែលធ្វើឡើង ដោយចៅក្រមដែលមានវិសមិតភាពធ្វើឱ្យសេចក្តីសម្រេចនោះអាចត្រូវបដិសេធដោយតុលាការកំពូល។

**ច. ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់**

សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដែលមិនបានពិចារណានឹងសម្រេចលើការស្នើសុំរបស់ភាគីខណៈពេលដែលការស្នើសុំបានធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យច្បាស់លាស់ធ្វើឱ្យតុលាការកំពូលអាចបដិសេធសេចក្តីសម្រេចបែបនេះរបស់តុលាការថ្នាក់ក្រោមបានផងដែរ។

ប្រសិនបើក្នុងករណី តុលាការកំពូលបានបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយហេតុថាកាលពីនៅសាលាឧទ្ធរណ៍ជនជាប់ចោទបានស្នើសុំដល់មហាអយ្យការឱ្យធ្វើការសាកសួរសាក្សីរបស់ខ្លួន ហើយក៏ដូចជានៅពេលសវនាការ ជនជាប់ចោទក៏នៅតែសំណូមពរដដែលដោយមានលិខិតស្នើសុំ តែសាលាឧទ្ធរណ៍ពុំបានលើកយកមកពិចារណានឹងសម្រេចសេចក្តីអំពីចំណុចនេះបានបំពានលើមាត្រា២០៩ ចំណុចទី៣ (ការប្រកែក ឬការខ្វះខាតមិនបានសម្រេចលើពាក្យសុំ ឬសេចក្តីសន្និដ្ឋានមួយឬច្រើនរបស់ភាគីណាមួយរួមមានអយ្យការផងដែលប្រើសិទ្ធិ ឬសេរីភាពរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ ឬច្បាប់ប្រគល់ឱ្យ) នៃច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ដែលចំណុចនេះមានខ្លឹមសារប្រហាក់ប្រហែលទៅនឹងមាត្រា៤១៩ ចំណុចទី៦ (ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគីកាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

**ឆ. ការបំភ្លៃអង្គហេតុ**

តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយមូលហេតុការបំភ្លៃអង្គហេតុ។ អង្គហេតុ គឺជាធាតុមួយដ៏សំខាន់សម្រាប់កំណត់អំពីអង្គច្បាប់ ដូចជាធាតុផ្សំនៃបទល្មើសជាអាទិ៍។ ការប្រែប្រួលនៃអង្គហេតុធ្វើឱ្យមានការសន្និដ្ឋានលើអង្គច្បាប់ផ្សេងផងដែរ ដូចជាពីមានបទល្មើសទៅជាគ្មានបទល្មើស។ អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍[65]ដែលបានលើកនៅពេលសវនាការ។

[65] ទឡ្ហីករណ៍ មានន័យថា ពាក្យ ឬសេចក្តីដែលសំអាង បញ្ជាក់ថាជាសេចក្តីពិត(វចនានុក្រមខ្មែរពុទ្ធសាសនបណ្ឌិត ទំព័រ៤៤១)

### ជ. គ្មានសំអាងហេតុ

សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដែលធ្វើឡើងដោយគ្មានសំអាងហេតុអាចត្រូវបានបដិសេធដោយតុលាការកំពូល។ ជាគោលការណ៍គ្រប់ការសម្រេចសេចក្តីរបស់តុលាការត្រូវមានសំអាងហេតុ។ សំអាងហេតុ គឺសំដៅទៅលើអំណះអំណាងនៃអង្គហេតុ និងអំណះអំណាងនៃអង្គច្បាប់នៃការសម្រេចសេចក្តីដោយមានសំអាងហេតុធ្វើឱ្យគេមានទំនុកចិត្តទៅលើសេចក្តីសម្រេចនោះ ដោយហេតុថាការសម្រេចសេចក្តីនោះមានហេតុផលហើយធ្វើឱ្យអ្នកដែលមិនពេញចិត្តនឹងការសម្រេចសេចក្តីនោះ មានមូលដ្ឋានដើម្បីអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន។ នៅក្នុងអង្គហេតុតុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី[66]។

### ឈ. ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច

ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេចក៏ជាមូលហេតុដែលអាចនាំឱ្យតុលាការកំពូលបដិសេធនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបានដែរ។ សំអាងហេតុគឺជាការយល់ឃើញរបស់តុលាការតាមរយៈការសន្និដ្ឋានទៅលើ អង្គហេតុ និងអង្គច្បាប់ ដើម្បីឈានទៅដល់ការសម្រេចសេចក្តីមួយ។ ដើម្បីឱ្យគេយល់បានពីមូលហេតុដែលនាំឱ្យមានការសម្រេចសេចក្តីមួយ គឺគេមើលទៅលើការយល់ឃើញ ឬសំអាងហេតុនៃសេចក្តីសម្រេចនោះ។ សំអាងហេតុត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងសេចក្តីសម្រេច កាលណាការសម្រេចសេចក្តីដែលផ្ទុយគ្នាពីសំអាងហេតុធ្វើឱ្យគេមិនអាចដឹងថាសេចក្តីសម្រេចនោះឈរលើមូលដ្ឋានអ្វីនោះទេ។ ផ្នែកសំអាងហេតុពោលគឺ ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច[67]។

ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធចោលសេចក្តីសម្រេចដែលត្រូវគេប្តឹងសាទុក្ខនេះមានអានុភាពយកទៅអនុវត្តបាន។ ភាគីដែលបណ្តឹងសាទុក្ខរបស់ខ្លួនត្រូវបដិសេធចោលមិនអាចប្តឹងសាទុក្ខបានទៀតឡើយចំពោះសាលដីកាដដែលនោះ ទោះលើកយកលេស ឬមធ្យោបាយអ្វីមកសំអាងក៏ដោយ[68] (លើកលែងតែករណីមានបណ្តឹងសើរើ)។

ការកំណត់អំពីមូលហេតុជាក់លាក់នៃបណ្តឹងសាទុក្ខ គឺដោយសារតែតុលាការកំពូលជាចៅក្រមអង្គច្បាប់មិនមែនជាចៅក្រមអង្គហេតុឡើយ។ មាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងជាក់ច្បាស់ថាតុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ និងដែលមានរៀបរាប់នៅក្នុងសារណា[69]។

---

[66] មាត្រា៣៥៧ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[67] មាត្រា៣៥៧ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68] មាត្រា២២០ កថាខណ្ឌទី២ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

[69] មាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២. ២. ២. បុគ្គលដែលអាចប្តឹងសាទុក្ខ

បណ្តឹងសាទុក្ខអាចធ្វើទៅបាន ដោយបុគ្គលដែលមានសិទ្ធិប្តឹងសាទុក្ខ តាមមាត្រា៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ មានដូចខាងក្រោម៖**

-**អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖** ជាតំណាងមហាអយ្យការអមតុលាការកំពូល ហើយមានតួនាទីសុំឱ្យមានការគោរពច្បាប់នៅក្នុងពេលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលត្រូវបានប្តឹងមកកាន់តុលាការកំពូល។ នៅពេលដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលពិនិត្យឃើញថាសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍មិនត្រឹមត្រូវ ឬការសម្រេចនោះមានការខ្វះចន្លោះអំពីទណ្ឌកម្ម ឬបទល្មើសណាមួយនោះ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការប្តឹងសាទុក្ខទៅនឹងសេចក្តីសម្រេចនោះបាន រួមទាំងភ្ជាប់ជាមួយនូវសារណានៃមូលហេតុបណ្តឹងសាទុក្ខផងដែរ។

-**អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** ជាតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ហើយតួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺធ្វើការឃ្លាំមើលការអនុវត្តច្បាប់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចដែលកំណត់ដោយច្បាប់ (សាលាឧទ្ធរណ៍តំបន់) មានន័យថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យរាល់ពាក្យបណ្តឹងដែលត្រូវបានប្តឹងមកកាន់សាលាឧទ្ធរណ៍ ដូចជាពាក្យបណ្តឹងពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការអមសាលាដំបូង ឬក៏ពិនិត្យពីសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលធ្វើឡើងមិនត្រឹមត្រូវតាមច្បាប់ ឬការសម្រេចនោះមានការខ្វះចន្លោះអំពីទណ្ឌកម្ម ឬបទល្មើសណាមួយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើបណ្តឹងសាទុក្ខមកកាន់តុលាការកំពូលរួមទាំងភ្ជាប់ជាមួយនូវសារណានៃមូលហេតុបណ្តឹងសាទុក្ខផងដែរ។

-**ជនជាប់ចោទ ឬពិរុទ្ធជន** ៖ ជនជាប់ចោទ គឺជាជនដែលត្រូវបានគេបញ្ជូនទៅជំនុំជម្រះនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។

ពិរុទ្ធជន គឺជាជនដែលត្រូវបានតុលាការព្រហ្មទណ្ឌប្រកាសថា មានពិរុទ្ធភាពក្នុងពេលសវនាការ ។

នៅពេលដែលជនជាប់ចោទ ឬពិរុទ្ធជនមានការមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដែលបានសម្រេចសេចក្តីមកលើខ្លួននោះ គឺជននោះអាចធ្វើបណ្តឹងសាទុក្ខមកកាន់តុលាការកំពូលតាមរយៈពេលដែលកំណត់ដោយច្បាប់[70]មាត្រា៤២០ (រយៈពេលដើម្បីធ្វើបណ្តឹងសាទុក្ខ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន៖** គឺសំដៅទៅលើបុគ្គលជាជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយកម្មវត្ថុនៃការប្តឹងទាមទារគឺពាក់ព័ន្ធនឹងបត្យាប័ន [71] ។ បុគ្គលដែលត្រូវបានគេ

[70] មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទាមទារនៅក្នុងនីតិវិធីបត្យាប័ននោះអាចធ្វើការប្តឹងសាទុក្ខមកកាន់តុលាការកំពូលអំពីបញ្ហានៃការសម្រេចអំពីការបញ្ជូនខ្លួនទៅតាមនីតិវិធីបត្យាប័ន។

**-ដើមបណ្តឹងរដ្ឋប្បវេណី៖** គឺធ្វើឡើងក្នុងនាមជាជនរងគ្រោះ កាលណាជនរងគ្រោះនោះជាអនីតិជន ឬជានីតិជនដែលស្ថិតនៅក្រោមរបបដែលច្បាប់កំណត់ ដោយដើមបណ្តឹងរដ្ឋប្បវេណីនោះគឺជាអ្នកតំណាងដោយស្របច្បាប់របស់អនីតិជន ឬជានីតិជនដែលស្ថិតនៅក្រោមរបបច្បាប់កំណត់ (អ្នកអាណាព្យាបាល) ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខមកកាន់តុលាការកំពូលបាន នៅពេលដែលខ្លួនមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលសម្រេចទាក់ទងទៅនឹងសំណងផ្នែករដ្ឋប្បវេណីដែលខ្លួនត្រូវទទួល ហើយខ្លួនយល់ថាការសម្រេចនេះគឺមិនត្រឹមត្រូវទៅតាមអ្វីដែរខ្លួនបានទាមទារ។

**-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី៖** អ្នកដែលទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី គឺជាជនទាំងឡាយណាដែលច្បាប់តម្រូវឱ្យទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណីចំពោះទង្វើរបស់ជនល្មើសដែលជននោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីដែលច្បាប់ទទួលស្គាល់។ ការទទួលខុសត្រូវរបស់ឪពុកម្តាយចំពោះកូនដែលជាអនីតិជន និងការទទួលខុសត្រូវរបស់និយោជកទៅលើអំពើរបស់និយោជិត។ ការប្តឹងសាទុក្ខមកកាន់តុលាការកំពូលរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីគឺនៅពេលដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណីយល់ឃើញថា សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលសម្រេចអំពីសំណងរដ្ឋប្បវេណីដែលខ្លួនត្រូវទទួលខុសត្រូវនោះ មិនសមស្របទៅនឹងអ្វីដែលខ្លួនអាចទទួលខុសត្រូវទេ ឬមិនសមស្របទៅនឹងច្បាប់។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចជា ឪពុកម្តាយ ឬអាណាព្យាបាលរបស់ជនល្មើសដែលជាអនីតិជន អ្នកមានសិទ្ធិជាអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈរបស់ជនល្មើស សិទ្ធិវន្តរបស់ជនល្មើស និយោជករបស់ជនល្មើស និងអាចជាក្រុមហ៊ុនធានារ៉ាប់រង។

### ២. ២. ៣. រយៈពេលនៃបណ្តឹងសាទុក្ខ

**បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចខាងក្រោម[72]៖**

-១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

-១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

-៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។

កាលណាសាលដីកាកំបាំងមុខត្រូវបានសម្រេចម្តងទៀតរួចហើយ ឬរយៈពេលប្តឹងទាស់បានកន្លងផុត ឬសាលដីកាចំពោះមុខរយៈពេលប្តឹងសាទុក្ខគិតពីពេលប្រកាសសាលដីកា។

[71] សូមអាន ជំពូកទី២ កថាភាគទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ត្រង់ចំណុចនេះ ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅដែនដីកម្ពុជា។

[72] មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាង ឆ្នាំ២០០៧

កាលណាសាលដីកាដែលប្ដឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្ដើមពីការឱ្យដំណឹង។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្ដើមគិតពីការផុតរយៈពេលប្ដឹងទាស់។

កាលណាសាលាឧទ្ធរណ៍ចេញសាលដីកាចាត់របៀប បណ្ដឹងសាទុក្ខត្រូវទទួលបានភ្លាមប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀប[73] (សាលដីកាមិនទាន់ដល់អង្គសេចក្ដីដោយគ្រាន់តែពិនិត្យបន្ថែមទៅលើភស្តុតាងដែលមាន) អាចដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្ដីតែប៉ុណ្ណោះ[74]។

## ២. ៣. ចំណាត់ការនៃបណ្ដឹងសាទុក្ខ

### ២. ៣. ១. ការចុះបញ្ជីសំណុំរឿង

នៅពេលដែលសំណុំរឿង បានមកដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី មាត្រា៤២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[75]។ ប៉ុន្តែជាក់ស្ដែងបច្ចុប្បន្ននៅពេលដែលសំណុំរឿងដែលបញ្ជូនពីសាលាឧទ្ធរណ៍មកដល់តុលាការកំពូល ការិយាល័យរដ្ឋបាលទូទៅជាអ្នកទទួលសំណុំរឿង និងចុះបញ្ជី[76]។ នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិកនៃអគ្គលេខាធិការដ្ឋានត្រូវចុះបញ្ជីរឿងក្ដីព្រហ្មទណ្ឌយ៉ាងយូរបំផុតមិនឱ្យលើសពីព្រឹកថ្ងៃធ្វើការបន្ទាប់ រួចដាក់ជូនប្រធានតុលាការកំពូលដើម្បីចាត់ចៅក្រមរបាយការណ៍[77]។ ដូចនេះនៅពេលដែលសំណុំរឿងមកដល់តុលាការកំពូល ការិយាល័យរដ្ឋបាលទូទៅត្រូវទទួលចុះបញ្ជីសំណុំរឿងក្នុងសៀវភៅទទួលសំណុំរឿង បន្ទាប់មកត្រូវបញ្ជូនទៅកាន់ប្រធានតុលាការកំពូលដើម្បីចាត់តាំងចៅក្រមរបាយការណ៍ដោយភ្ជាប់ជាមួយនឹងដីកាសម្រេចចាត់តាំងចៅក្រមរបាយការណ៍។ បន្ទាប់មកចៅក្រមរបាយការណ៍នោះត្រូវប្រគល់សំណុំរឿងទៅឱ្យក្រឡាបញ្ជីនៃតុលាការកំពូលដើម្បចាត់ការនីតិវិធី ដូចជាជូនដំណឹងអំពីការចុះបញ្ជីនៃសំណុំរឿង, លិខិតបង្គាប់ឱ្យដាក់សារណាការពារ និងលិខិតបង្គាប់ឱ្យដាក់សារណាតប។

### ២. ៣. ២. រយៈពេលធ្វើសារណា

ក្រឡាបញ្ជីនៃតុលាការកំពូលត្រូវជូនដំណឹងដល់គូភាគីអំពីការចុះបញ្ជីនៃសំណុំរឿង។ ការជូនដំណឹងនៅក្នុងន័យនេះ គឺសំដៅទៅដល់ការជូនដំណឹងរបស់ក្រឡាបញ្ជីនៃតុលាការកំពូលទៅកាន់អ្នកប្ដឹងសាទុក្ខ និង

[73] សាលដីកាចាត់របៀប (សាលដីកាមិនទាន់ដល់អង្គសេចក្ដី) គឺជាសាលដីកាដែលសម្រេចអំពីបញ្ហានីតិវិធីហើយមិនជំនុំជម្រះដល់អង្គសេចក្ដីនោះទេ ប៉ុន្តែនៅពេលលេចឡើងនូវអញ្ញតកម្ម ឬអង្គហេតុថ្មី ត្រូវចាត់របៀប។

[74] មាត្រា៤២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា៤២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[76] សេចក្ដីសម្រេច ស្ដីពីការផ្ទេរការគ្រប់គ្រងកិច្ចការរដ្ឋបាលតុលាការដល់ការិយាល័យជំនាញនៃអគ្គលេខាដ្ឋានរដ្ឋបាលតុលាការកំពូល លេខ, ៣៤៩/១៦ តកក.រ.ប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

[77] ប្រការ៤ នៃដីកាសម្រេច លេខ៥៥៤ តកក២០១៦ ស្ដីពីការបែងចែកសំណុំរឿង និងការចាត់ចែងរដ្ឋបាល រឿងក្ដីព្រហ្មទណ្ឌ

ភាគីដែលពាក់ព័ន្ធអំពីការចុះបញ្ជីនៃសំណុំរឿង។ បន្ទាប់មកក្រឡាបញ្ជីត្រូវធ្វើលិខិតជូនដំណឹងទៅកាន់អ្នកប្ដឹងសាទុក្ខឱ្យដាក់សារណាការពារដើម្បីរៀបរាប់អំពីមូលហេតុដែលប្ដឹងសាទុក្ខមកកាន់តុលាការកំពូល ក៏ដូចជាការរៀបរាប់អំពីមធ្យោបាយខាងផ្លូវច្បាប់។ ប្រសិនបើក្នុងករណីដែលអ្នកប្ដឹងសាទុក្ខនោះមានមេធាវីការពារសិទ្ធិ និងមានលិខិតពឹងពាក់មេធាវីត្រឹមត្រូវ ការជូនដំណឹងនេះក៏ត្រូវបានបញ្ជូនទៅកាន់មេធាវីនោះផងដែរ។ អ្នកប្ដឹងសាទុក្ខអាចតាំងមេធាវីរបស់ខ្លួនបាន ចាប់ពីសំណុំរឿងនោះត្រូវបានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីរបស់តុលាការកំពូលរហូតដល់មុនថ្ងៃសវនាការ ០១ (មួយ) ថ្ងៃ ។

លិខិតបង្គាប់ឱ្យដាក់សារណាការពារកំណត់រយៈពេល ២០ថ្ងៃ[78] គិតចាប់ពីថ្ងៃដែលអ្នកប្ដឹងសាទុក្ខបានទទួលលិខិតជូនដំណឹងនេះ។ នៅពេលដែលអ្នកប្ដឹងសាទុក្ខបានដាក់សារណាការពារមកកាន់តុលាការហើយនោះ ក្រឡាបញ្ជីត្រូវជូនដំណឹងបង្គាប់ឱ្យចុងបណ្ដឹងសាទុក្ខដាក់សារណាតបមកតុលាការកំពូលវិញម្ដងដើម្បីឆ្លើយតបទៅនឹងសារណាការពាររបស់អ្នកប្ដឹងសាទុក្ខ។ លិខិតបង្គាប់ឱ្យដាក់សារណាតបមានរយៈពេល ២០ (ម្ភៃ)ថ្ងៃ ដូចគ្នានឹងលិខិតបង្គាប់ឱ្យដាក់សារណាការពារដែរ គឺគិតចាប់ពីថ្ងៃដែលបានទទួលលិខិតនេះ។ ក្នុងករណីដែលអ្នកប្ដឹងសាទុក្ខមិនបានដាក់សារណាការពារមកកាន់តុលាការកំពូលក្នុងរយៈពេល ២០(ម្ភៃ) ថ្ងៃ ដែលបានកំណត់ទេនោះ អ្នកប្ដឹងសាទុក្ខអាចដាក់ពាក្យសុំពន្យារពេលនៃការដាក់សារណាការពារនេះមកកាន់តុលាការកំពូលដោយមានមូលហេតុសមរម្យ។ ការពន្យារពេលនេះមិនអាចលើសពី ១០ថ្ងៃបានទេ មានន័យថាការពន្យារពេលបានត្រឹមតែ១០ថ្ងៃប៉ុណ្ណោះ។

### ២. ៣. ៣. ការចាត់តាំងចៅក្រមរបាយការណ៍

លុះដល់ផុតរយៈពេលកំណត់ដើម្បីដាក់សារណា ឬក៏អ្នកប្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខបានអនុវត្តតាមនីតិវិធីដោយដាក់សារណាមកតុលាការកំពូលរួចរាល់ហើយនោះ ប្រធានតុលាការកំពូលនឹងចាត់តាំងចៅក្រមរបាយការណ៍ម្នាក់រួចបញ្ជូនសំណុំរឿងទៅចៅក្រមរបាយការណ៍នោះ ដោយមានភ្ជាប់សារណាទៅជាមួយផង[79] ដើម្បីចៅក្រមរបាយការណ៍សរសេររបាយការណ៍តាមមាត្រា៤៣១ (ការសរសេររបាយការណ៍) និងចាត់ការតាមមាត្រា៤៣២ (ការបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញានិងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ[80]។

ចៅក្រមរបាយការណ៍នោះត្រូវធ្វើរបាយការណ៍អំពីសំណុំរឿង ហើយរបាយការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានទម្រង់ដូចជា៖

-សាវតាជាតិរបស់ជនជាប់ចោទ ឬជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

[78] មាត្រា៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[79] មាត្រា ៤៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[80] ប្រការ៧ នៃដីកាសម្រេច លេខ៥៥៤ គកក២០១៦ ស្ដីពីការបែងចែកសំណុំរឿង និងការចាត់ចែងរដ្ឋបាល រឿងក្ដីព្រហ្មទណ្ឌ

ប្តឹងផ្តល់ ជនរងគ្រោះ អ្នកតំណាង (មេធាវី អ្នកតំណាងឱ្យជនរងគ្រោះ)។

-នីតិវិធី និងអង្គហេតុៈ ចៅក្រមរបាយការណ៍ត្រូវរៀបរាប់អំពីអង្គហេតុដែលជាអង្គហេតុនៃរឿងក្តីនោះ ព្រមជាមួយនឹងនីតិវិធីរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ដែលចាត់ការទៅលើរឿងក្តីនោះ។

-ចំណុចច្បាប់ដែលភាគីបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់សាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ព្រមជាមួយនឹងដំណោះស្រាយដែលចៅក្រមរបាយការណ៍ត្រូវលើកឡើងនៅក្នុងទម្រង់ច្បាប់ គតិច្បាប់នៅក្នុងរបាយការណ៍នោះ[81]។

បន្ទាប់ពីធ្វើរបាយការណ៍នោះរួច ចៅក្រមរបាយការណ៍ត្រូវដាក់របាយការណ៍នោះក្នុងសំណុំរឿង បន្ទាប់មកត្រូវបញ្ជូនសំណុំរឿងទៅឱ្យស្ថាប័នមហាអយ្យការអមតុលាការកំពូល ដើម្បីធ្វើសេចក្តីសន្និដ្ឋានតាមច្បាប់កំណត់។

### ២. ៣. ៤. ការបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋាន

បន្ទាប់ពីចៅក្រមរបាយការណ៍ធ្វើរបាយការណ៍រួចហើយនោះសំណុំរឿង នោះត្រូវបានបញ្ជូនមកកាន់មហាអយ្យការអមតុលាការកំពូល ដោយមានសារណា និងរបាយការណ៍មកជាមួយ[82]។

នៅពេលដែលសំណុំរឿងនោះត្រូវបានបញ្ជូនទៅកាន់មហាអយ្យការ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលធ្វើការបែងចែកសំណុំរឿងក្តីនោះទៅឱ្យអគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញាធ្វើការពិនិត្យ និងធ្វើសេចក្តីសន្និដ្ឋាន។ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងសេចក្តីសន្និដ្ឋាននោះត្រូវមានៈ

- សាវតាជាតិរបស់ជនជាប់ចោទ ឬជនត្រូវចោទ
- នីតិវិធីនៃការសម្រេចសេចក្តីរបស់តុលាការថ្នាក់ក្រោម
- ការយល់ឃើញរបស់មហាអយ្យការ (មានទម្រង់ច្បាប់ និងគតិច្បាប់)
- សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ។

បន្ទាប់ពីមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានរួចហើយ ត្រូវបញ្ជូនមកប្រធានតុលាការកំពូលដើម្បីកំណត់កាលបរិច្ឆេទសវនាការ ក៏ប៉ុន្តែមុននឹងបញ្ជូនត្រលប់មកប្រធានតុលាការកំពូលវិញនោះ មហាអយ្យការត្រូវឆ្លងកាត់ការឯកភាព និងយល់ព្រមពីអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលសិន ទើបធ្វើការបញ្ជូនត្រឡប់មកប្រធានតុលាការកំពូល ដើម្បីកំណត់ថ្ងៃសវនាការ។ នៅពេលដែលថ្ងៃបរិច្ឆេទនៃសវនាការត្រូវបានកំណត់រួចហើយនោះ ប្រធានតុលាការត្រូវជូនដំណឹងមកកាន់មហាអយ្យការអំពីកាលបរិច្ឆេទនៃសវនាការនោះ។ បន្ទាប់មកមហាអយ្យការត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនោះទៅកាន់ភាគីដែលពាក់ព័ន្ធរួមនឹងមេធាវីផងដែរ។

សំណុំរឿងដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលបានសន្និដ្ឋានរួច និងបង្វិលមកវិញ ហើយត្រូវចុះបញ្ជីភ្លាមៗតាមលំដាប់លេខរៀងដាក់ជូនប្រធានតុលាការកំពូលដើម្បីចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ និងកំណត់

[81] មាត្រា ៤៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[82] មាត្រា៤៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កាលបរិច្ឆេទសវនាការដើម្បីឱ្យអគ្គព្រះរាជអាជ្ញាចាត់ការតាមមាត្រា ៤៣៣ (ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគី)នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

# ជំពូកទី៣
# ការជំនុំជម្រះ
# និងការបោះបង់ចោល
# បណ្តឹងសារទុក្ខ

# ជំពូកទី៣

# ការជំនុំជម្រះ និងការបោះបង់ចោលបណ្ដឹងសាទុក្ខ

## ៣. ១. នីតិវិធីជំនុំជម្រះ

### ៣. ១. ១. ការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការ

ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការនេះ បន្ទាប់មកអគ្គព្រះរាជអាជ្ញាឱ្យដំណឹងកាលបរិច្ឆេទនេះដល់ជនត្រូវចោទ ឬជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងមេធាវី-ល-។

ការឱ្យដំណឹងដល់ពិរុទ្ធជន ឬជនជាប់ចោទនៅក្រៅឃុំ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ កាលណាការឱ្យដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យដំណឹងនៅក្នុងសំណុំរឿង។ ពិរុទ្ធជន ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬមេធាវីត្រូវផ្ដិតក្រយៅមេដៃស្ដាំ ឬចុះហត្ថលេខាទទួលលិខិតជូនដំណឹងនេះ។ នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់[83]។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមក្រុមប្រឹក្សានីមួយៗត្រូវចាត់តាំងដោយប្រធានតុលាការកំពូលតាមលំដាប់បន្តបន្ទាប់ស្របនឹងបញ្ជីតារាងប្រចាំឆ្នាំដែលបានរៀបចំរួច ឬក្នុងលក្ខខណ្ឌដោយមានវត្តមាន និងគ្មានវិសមិតភាព [84] ។ ក្រុមប្រឹក្សាជំនុំជម្រះនេះមានសមត្ថកិច្ចជំនុំជម្រះលើសំណុំរឿងបណ្ដឹងសាទុក្ខលើកទី១ លើសាលដីកានៃសភាស៊ើបសួរ រឿងបត្យាប័ន រឿងស្រូបទោស និងបណ្ដឹងទាក់ទងនឹងការអនុវត្តទោស បណ្ដឹងសុំបកស្រាយសេចក្ដីសម្រេច លើកលែងតែក្នុងករណីមានវិសមិតភាព[85]។

រាល់សវនាការដែលបានជំនុំជម្រះរួច ត្រូវសម្រេចនូវសាលដីកាមិនឱ្យលើសពី ១៥ថ្ងៃ រួចបញ្ជូនទៅមហាអយ្យការអមតុលាការកំពូលដើម្បីបញ្ជូនសាលដីកាស្ថាពរនោះទៅជនជាប់ចោទ ឬជនត្រូវចោទ-ល-។ ប៉ុន្តែចំពោះសាលដីកាដែលសម្រេចដោះលែងជនដែលកំពុងឃុំខ្លួន ឬសម្រេចចាប់ខ្លួនត្រូវធ្វើឱ្យឆាប់ដើម្បីអនុវត្តមិនឱ្យលើសពី ០១ថ្ងៃ[86]។

---

[83] មាត្រា៤៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[84]វិសមិតភាព (ភាពដែលមិនអាចមាន ឬមិនអាចធ្វើចូលគ្នាបាន) ។ វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពលើកទី៤ ឆ្នាំ ២០១៨ ទំព័រ ១៣៨៨

[85] ប្រការ១២ នៃដីកាសម្រេច លេខ៥៥៤ តកក២០១៦ ស្ដីពីការបែងចែកសំណុំរឿង និងការចាត់ចែងរដ្ឋបាល រឿងក្ដីព្រហ្មទណ្ឌ ឆ្នាំ ២០១៧

[86]ប្រការ១៨ នៃដីកាសម្រេចលេខ៥៥៤ តកក២០១៦ ស្ដីពីការបែងចែកសំណុំរឿង និងការចាត់ចែងរដ្ឋបាល រឿងក្ដីព្រហ្មទណ្ឌ ឆ្នាំ ២០១៧

### ៣. ១. ២. ការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១

សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកាផ្នែកព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍។ ការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយមានចៅក្រមចំនួន ០៥(ប្រាំ) រូប ក្នុងនោះមានចៅក្រមមួយរូបជម្រះក្នុងនាមជាប្រធានសភាព្រហ្មទណ្ឌ ឬមួយរូបត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូលដើម្បីធ្វើជាប្រធានអង្គជំនុំជម្រះដើម្បីដឹកនាំកិច្ចនីតិវិធីក្នុងពេលជំនុំជម្រះ។ ដោយហេតុថា តុលាការកំពូលជាតុលាការអង្គច្បាប់ ដូច្នេះតុលាការកំពូលនឹងជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១ ដោយពិនិត្យលើអង្គច្បាប់ដែលតុលាការថ្នាក់ក្រោមអនុវត្ត ។

**ចំពោះសកម្មភាពជំនុំជម្រះចាប់ផ្តើមដោយៈ**

ក-ប្រធានអង្គជំនុំជម្រះប្រកាសបើកសវនាការជំនុំជម្រះលើបណ្តឹងសាទុក្ខដោយប្រកាសពីសមាសភាពនៃសមាជិកភាពនៃសមាជិកអង្គសវនាការដែលបានចូលរួមជំនុំជម្រះមានចៅក្រមប្រឹក្សា ក្រឡាបញ្ជី និងតំណាងមហាអយ្យការ ។

ខ-ប្រធានអង្គសវនាការប្រកាសអំពីសញ្ញាណនៃសំណុំរឿងដែលត្រូវធ្វើការជំនុំជម្រះដោយបង្ហាញពីប្រភេទបទល្មើស អង្គហេតុ ក៏ដូចជាឈ្មោះជនជាប់ចោទ/ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី រួមទាំងមេធាវីការពារសិទ្ធិផងដែរ។

គ-ប្រធានអង្គសវនាការបង្គាប់ឱ្យក្រឡាបញ្ជីរាយការណ៍ពីវត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនឹងសំណុំរឿង។

ឃ-ប្រធានអង្គសវនាការបង្គាប់ឱ្យចៅក្រមរបាយការណ៍អានរបាយការណ៍នៃសំណុំរឿងដោយមានរៀបរាប់អំពីដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះរបស់ប្រធានតុលាការកំពូល ឈ្មោះ និងអាសយដ្ឋានរបស់ជនជាប់ចោទ/ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវី អង្គហេតុប្រភេទបទល្មើសដែលបានចោទប្រកាន់ និងដំណើរការនៃនីតិវិធីព្រមទាំងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមទម្រង់ច្បាប់នៃបណ្តឹងសាទុក្ខ សារណាការពារ និងសារណាតបដែលចុងបណ្តឹងសាទុក្ខបានដាក់មកតុលាការកំពូល។

ង-ក្រោយពីចៅក្រមរបាយការណ៍អានសារណាចប់ ប្រធានអង្គសវនាការអនុញ្ញាតឱ្យតំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន។ ករណីផ្សេងទៀត ដែលអ្នកប្តឹងសាទុក្ខជាអគ្គព្រះរាជអាជ្ញា ប្រធានអង្គសវនាការបង្គាប់ឱ្យក្រឡាបញ្ជីអានសារណារបស់អគ្គព្រះរាជអាជ្ញា បន្ទាប់មកទើបអញ្ជើញតំណាងមហាអយ្យការឱ្យធ្វើការកត់សម្គាល់ផ្ទាល់មាត់ (មាត្រា ៣០ ក្រមនីតិវិធីព្រហ្មទណ្ឌ និងមត្រា ៧០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការៀបចំអង្គការតុលាការ)។

ច-បន្ទាប់មកប្រធានអង្គសវនាការ ចាប់ផ្ដើមសួរអត្តសញ្ញាណអ្នកប្ដឹងសាទុក្ខដូចជាឈ្មោះ ភេទ អាយុ សញ្ជាតិ មុខរបរ ទីន្លែងកំណើត ទីលំនៅបច្ចុប្បន្ន ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធឬប្ដី ចំនួនកូន និង ប្រវត្តិនៃការផ្ដន្ទាទោសពីមុន។ រួចមកទៀតប្រធាននឹងសួរអំពីមេធាវីការពារសិទ្ធិ មូលហេតុនៃការប្ដឹងមិនសុខចិត្ត សាលដីកាសាលាឧទ្ធរណ៍ និងសំណូមពរអ្វីបន្ថែមលើសារណាទៀតទេប្រសិនបើមាន។ ហើយបន្ទាប់មក ប្រធានអង្គសវនាការនឹងបន្តាប់ឱ្យអ្នកប្ដឹងសាទុក្ខថយទៅកន្លែងវិញ។

ឆ-បន្ទាប់មកប្រធាននឹងអញ្ជើញមេធាវីការពារឱ្យអ្នកប្ដឹងសាទុក្ខ និងមេធាវីការពារឱ្យចុងបណ្ដឹងសាទុក្ខ ឡើងធ្វើសេចក្ដីសន្និដ្ឋាន រួចក៏ប្រកាសបញ្ចប់ការសួរដេញដោល ហើយអង្គជំនុំជម្រះនឹងថយទៅពិភាក្សា។

### ៣.១.២.១.ការបដិសេធដោយគ្មានការបង្វិលសំណុំរឿង

កាលណាអំពើដែលចោទប្រកាន់មិនមែនជាបទល្មើសទេ តុលាការកំពូលប្រកាសបដិសេធសាលដីកា របស់សាលាឧទ្ធរណ៍ដោយគ្មានបង្វិលសំណុំរឿងទៅវិញឡើយ[87]។ ក្នុងករណីនេះ តុលាការកំពូលនឹងសម្រេច ឱ្យជនជាប់ចោទ ឬជនត្រូវចោទរួចខ្លួនពីបទចោទប្រកាន់ ប្រសិនបើអង្គហេតុដែលចោទប្រកាន់ដោយតុលាការ ថ្នាក់ក្រោមនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ*(ឧទាហរណ៍ អង្គហេតុនៃបទល្មើសរំលោភទំនុកចិត្ត ដែលក្រោយ ពីចោទប្រកាន់មកតុលាការកំពូលរកឃើញថា អង្គហេតុនោះពុំមែនជាបទល្មើសព្រហ្មទណ្ឌទេ)*។

### ៣.១.២.២.ការបដិសេធដោយមានការបង្វិលសំណុំរឿង

កាលណាតុលាការកំពូលយល់ថា បទល្មើសដែលតុលាការថ្នាក់ក្រោមរកឃើញខុសពីបទល្មើសដែល តុលាការកំពូលរកឃើញ នោះតុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ហើយបង្វិលទៅ សាលាឧទ្ធរណ៍ឱ្យសម្រេចជាថ្មី ក៏ប៉ុន្តែប្រសិនបើបទល្មើសនោះត្រូវផ្ដន្ទាទោសដូចគ្នា តុលាការកំពូលមិន ចាំបាច់ប្រកាសបដិសេធតែអាចកែប្រែប្រភេទគតិយុត្តនៃបទល្មើស (ឈ្មោះបទល្មើស) ដោយរក្សាទោសដែល បានប្រកាសហើយ និងរក្សាសេចក្ដីសម្រេចផ្នែកសំណងរដ្ឋប្បវេណីឱ្យនៅដដែល។ ករណីមួយទៀតប្រសិនបើ តុលាការកំពូលយល់ឃើញថា អំពើដែលត្រូវបានចោទប្រកាន់នោះ ជាបទល្មើសមួយផ្សេងពីបទល្មើសដែលត្រូវ បានសម្រេចនៅក្នុងសេចក្ដីសម្រេចដែលត្រូវបានប្ដឹងតវ៉ាមកតុលាការកំពូលហើយការផ្ដន្ទាទោស គឺមានលក្ខណៈ ផ្សេងពីគ្នា នោះតុលាការកំពូលត្រូវបដិសេធការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ និងបញ្ជូនសំណុំរឿងនោះ ទៅកាន់សាលាជំម្រះក្ដីដែលមានសមត្ថកិច្ច (សាលាឧទ្ធរណ៍) ដើម្បីជំនុំជម្រះឡើងវិញ។

### ៣. ១. ៣. ការជំនុំជម្រះលើបណ្ដឹងសាទុក្ខលើកទី២

ករណីដែលតុលាការកំពូលបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មី ហើយក្រោយពី សម្រេចរួចមក សាលាឧទ្ធរណ៍មិនស្របតាមការយល់ឃើញរបស់តុលាការកំពូល ហើយរឿងក្ដីដដែលនេះត្រូវ

[87] មាត្រា៤៤០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បានប្ដឹងសាទុក្ខលើកទី២មកកាន់តុលាការកំពូល នោះតុលាការកំពូលនឹងធ្វើការជំនុំជម្រះទៅលើសំណុំរឿងនោះម្ដងទៀតតាមខ្លឹមសារនៃ មាត្រា៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គដោយសម្រេចសេចក្ដីទាំងអង្គហេតុ និងអង្គច្បាប់ ហើយចេញនូវសេចក្ដីសម្រេចជាសាលដីកាស្ថាពរមួយ[88]។

នីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងសាទុក្ខលើកទី២ ក៏មិនខុសប្លែកពីនីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងសាទុក្ខលើកទី១ ប៉ុន្មានដែរ លើកលែងតែសមាសភាពជំនុំជម្រះដែលត្រូវមានចៅក្រមយ៉ាងតិចចំនួន ០៩រូប តាមមាត្រា៦២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ។ ម៉្យាងវិញទៀត ក្រុមប្រឹក្សាជំនុំជម្រះនៃសភាពេញអង្គនេះមានសមត្ថកិច្ចជំនុំជម្រះលើសំណុំរឿងបណ្ដឹងសាទុក្ខលើកទី២ និងបណ្ដឹងសើរើ បណ្ដឹងសុំបកស្រាយសេចក្ដីសម្រេច បណ្ដឹងសុំកែតម្រូវសេចក្ដីសម្រេច លើកលែងតែក្នុងករណីមានវិសមិតភាព។

សភាពេញអង្គបើកការជំនុំជម្រះទាំងអង្គច្បាប់ និងអង្គហេតុ ដោយពិនិត្យលើការសម្រេចសេចក្ដីរបស់តុលាការថ្នាក់ក្រោមក្នុងការបកស្រាយច្បាប់ ការអនុវត្តច្បាប់ ព្រមទាំងអាចកែប្រែលើអង្គសេចក្ដីដែលតុលាការថ្នាក់ក្រោមសម្រេចទៀតផង ***ឧទាហរណ៍*** *តុលាការថ្នាក់ក្រោមសម្រេចផ្ដន្ទាទោសបុគ្គល "ក" លើបទល្មើស ហិង្សាដោយចេតនា មាត្រា ២១៧ នៃក្រមព្រហទណ្ឌ ដោយតុលាការថ្នាក់ក្រោម ផ្ដន្ទាទោសបុគ្គលនោះចំនួន ០៣ (បី) ឆ្នាំដែលជាការកំណត់ ទោសអតិបរិមា ក្នុងបទល្មើសហិង្សាដោយចេតនា ដូច្នេះ តុលាការកំពូលអាចសម្រេចសេចក្ដីដោយកែប្រែការផ្ដន្ទាទោសបុគ្គល "ក" មកជា ០២ (ពីរ) ឆ្នាំវិញបាន បើតុលាការកំពូលយល់ឃើញថាធ្ងន់ល្មមនឹងអំពើរបស់ជនជាប់ចោទ។*

ដោយហេតុថាសេចក្ដីសម្រេចរបស់តុលាការនៃបណ្ដឹងសាទុក្ខជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយសេចក្ដីសម្រេចនេះអាចក្លាយទៅជាយុត្តិសាស្ត្រសម្រាប់ឱ្យតុលាការថ្នាក់ក្រោមធ្វើការអនុវត្តតាម។

### ៣. ១. ៤. អានុភាពនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខលើកទី២

ការសម្រេចសេចក្ដីរបស់តុលាការកំពូលអាចចេញជាលទ្ធផលដូចជា៖ បដិសេធបណ្ដឹងសាទុក្ខ, ទទួលបណ្ដឹងសាទុក្ខ និងមិនទទួលជំនុំជម្រះលើបណ្ដឹងសាទុក្ខ។

ការបដិសេធបណ្ដឹងសាទុក្ខរបស់តុលាការកំពូល គឺដោយសារតែបណ្ដឹងសាទុក្ខនោះវាពុំត្រូវនឹងមូលហេតុណាមួយនៃបណ្ដឹងសាទុក្ខ។ នៅពេលដែលបណ្ដឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្ដីសម្រេចដែលតុលាការថ្នាក់ក្រោមបានសម្រេចនោះមានអានុភាពស្ថាពរ ហើយអ្នកប្ដឹងសាទុក្ខមិនអាចប្ដឹងសាទុក្ខសាជាថ្មីអំពីសេចក្ដីសម្រេចស្ថាពរនោះបានទេ។

ការទទួលបណ្ដឹងសាទុក្ខរបស់តុលាការកំពូល គឺដោយសារតែបណ្ដឹងសាទុក្ខនោះត្រូវនឹងមូលហេតុណាមួយនៃបណ្ដឹងសាទុក្ខ*(មូលហេតុនៃបណ្ដឹងសាទុក្ខក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)* នោះតុលាការ

[88] មាត្រា៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កំពូលនឹងបដិសេធសាលដីការបស់តុលាការថ្នាក់ក្រោមរួចសម្រេចជាថ្មី។ ចំពោះបណ្តឹងសាទុក្ខលើកទី២ តុលាការកំពូលនឹងជំនុំជម្រះទាំងអង្គហេតុ និងអង្គច្បាប់។

ការមិនទទួលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់តុលាការកំពូល គឺដោយសារតែបណ្តឹងខុសច្បាប់ (*ឧទាហរណ៍ បណ្តឹងសាទុក្ខហួសកំណត់ច្បាប់*) ឬបុគ្គលដែលប្តឹងសាទុក្ខពុំគោរពតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ *(ឧទាហរណ៍ មេធាវីដែលធ្វើបណ្តឹងសាទុក្ខពុំមានលិខិតទទួលសិទ្ធិប្តឹងសាទុក្ខ) -ល-។*

## ៣. ២. ការបោះបង់ចោលបណ្តឹងសាទុក្ខ

### ៣. ២. ១. អំពីការបោះបង់ចោលបណ្តឹងសាទុក្ខ

តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យបោះបង់ថ្នាក់ពាក្យកិរិយាស័ព្ទ ហើយមានន័យថា គឺជាការលះបង់ចោលមិននឹកនា មិនថែទាំ។ ចំណែកពាក្យសាទុក្ខ គឺមានថ្នាក់ជាកិរិយាស័ព្ទ ហើយមានន័យថា ការនិយាយសេចក្តីទុក្ខរបស់ខ្លួន។

យោងតាមអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌបណ្តឹងសាទុក្ខសំដៅទៅលើបណ្តឹងឧបាស្រ័យ [89] ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍មកកាន់តុលាការកំពូល ដោយធ្វើឡើងដោយអ្នកមានសិទ្ធិអាចធ្វើបណ្តឹងសាទុក្ខ។ ចំពោះការបោះបង់បណ្តឹងសាទុក្ខ ជាសកម្មភាពដែលបុគ្គលណាមួយលះបង់សេចក្តីប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ដោយជាការដកបណ្តឹង ឬបោះបង់ចោលបណ្តឹងសាទុក្ខនោះវិញ។ សកម្មភាពបែបនេះធ្វើឱ្យសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចមកហើយនោះចូលជាស្ថាពរ។ ទោះបីជា នីតិវិធីបណ្តឹងកំពុងដំណើរការ ឬរហូតដល់នីតិវិធីសវនការ ក៏អ្នកប្តឹងសាទុក្ខអាចបោះបង់បណ្តឹងសាទុក្ខបានដែរ រហូតដល់មុនពេលដែលប្រធានអង្គជំនុំជម្រះ និងចៅក្រមប្រឹក្សាថយទៅពិភាក្សា។

ជនជាប់ចោទ ពិរុទ្ធជន បុគ្គលដែលត្រូវទាមទារក្នុងរឿងបត្យាប័ន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចបោះបង់ចោលបណ្តឹងសាទុក្ខរបស់ខ្លួន។ ការបោះបង់ចោលនេះត្រូវពិនិត្យកត់ត្រាដោយប្រធានសភាព្រហ្មទណ្ឌនៃតុលាការកំពូល[90]។

### ៣. ២. ២. របៀបបោះបង់ចោលបណ្តឹងសាទុក្ខ

**ក-អំឡុងពេលចំណាត់ការបណ្តឹងសាទុក្ខ**

ការបោះបង់ចោលបណ្តឹងសាទុក្ខនេះអាចធ្វើតាមរយៈលិខិតជាលាយល័ក្ខណ៍អក្សរដាក់ជូនមកតុលាការកំពូល អំឡុងពេលចំណាត់ការនីតិវិធីបណ្តឹងសាទុក្ខរបស់តុលាការកំពូល ដោយមានស្នាមក្រយៅដៃរបស់

---

[89] បណ្តឹងឧបាស្រ័យ (បណ្តឹងតវ៉ារបស់ភាគីដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ(សាលក្រម សាលដីកា ដីកាសម្រេច) របស់ចៅក្រម ឬតុលាការ ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។ (វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ៦៦៧

[90] មាត្រា ៤៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ២០១០

អ្នកប្តឹងសាទុក្ខ។

**ខ-អំឡុងពេលសវនាការ**

ប្រសិនបើចំណាត់ការនីតិវិធីបណ្តឹងសាទុក្ខដល់ដំណាក់កាលជំនុំជម្រះ អ្នកប្តឹងសាទុក្ខនៅតែអាចបោះបង់បណ្តឹងសាទុក្ខរបស់ខ្លួន ដែលអ្នកប្តឹងសាទុក្ខអាចប្រកាសពីការបោះបង់នេះនៅពេលសវនាការ។ នៅពេលដែលមានការបោះបង់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រាអំពីការបោះបង់បណ្តឹងសាទុក្ខនោះក្នុងកំណត់ហេតុសវនាការ។ មានន័យថា អ្នកប្តឹងសាទុក្ខបាននិយាយ ឬប្រកាសនាពេលសវនាការយ៉ាងជាក់ច្បាស់ថាខ្លួនមានបំណងបោះបង់ចោលការប្តឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍។

**៣. ២. ៣. អានុភាពនៃការដកបណ្តឹងសាទុក្ខ**

ការបោះបង់បណ្តឹងសាទុក្ខនាំឱ្យសាលដីការបស់សាលាឧទ្ធរណ៍ចូលជាស្ថាពរ។ ការចូលជាស្ថាពរនាំឱ្យសាលដីកាមានអនុភាពពេញលេញទាំងទណ្ឌកម្ម ទោសពិន័យ និងសំណងជំងឺចិត្តផងដែរ។ បទល្មើសព្រហ្មទណ្ឌនាំឱ្យមានបណ្តឹងពីរប្រភេទ គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ដូច្នេះប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីចង់ទាមទារសំណងការខូចខាតពីពិរុទ្ធជននោះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដើម្បីយករូបមន្តមកអនុវត្តសំណងរដ្ឋប្បវេណី។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានរៀបរាប់អំពីនីតិវិធីរបស់តុលាការកំពូលខាងលើនេះរួចមកឃើញថានីតិវិធីនៃបណ្តឹងសាទុក្ខរបស់តុលាការកំពូលគឺធ្វើឡើងចាប់ពីពេលសំណុំរឿងនោះ បានចុះបញ្ជីសំណុំរឿងនៅក្នុងតុលាការកំពូល។ ការអនុវត្តនីតិវិធីរបស់តុលាការកំពូលគឺផ្អែកទៅតាមការកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីបណ្តឹងសាទុក្ខនៅតុលាការកំពូល កំណត់ពីគោលបំណង មូលហេតុ និងនីតិវិធីនៃការដាក់ពាក្យបណ្តឹងរហូតដល់ដំណាក់កាលនៃការជំនុំជម្រះ ហើយចុងក្រោយចេញសេចក្តីសម្រេចស្ថាពរមួយដែលអាចបញ្ចប់រឿងនោះ។

ការជំនុំជម្រះលើបណ្តឹងសាទុក្ខមកកាន់តុលាការកំពូល ជាការជំនុំជម្រះលើកចុងក្រោយនៃសាលាជម្រះក្តី។ ក្រោយពីការជំនុំជម្រះ តុលាការកំពូលអាចសម្រេចសេចក្តីដោយប្រកាស សេចក្តីសម្រេចដែលសេចក្តីសម្រេចនោះអាចបដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែកអាចបដិសេធសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមទាំងស្រុង ឬមួយផ្នែកការបដិសេធបណ្តឹងសាទុក្ខនេះអាចនាំឱ្យការផ្តន្ទាទោស ឬសាលដីកាចូលជាស្ថាពរ ហើយអ្នកប្តឹងសាទុក្ខមិនអនុញ្ញាតឱ្យប្តឹងសាទុក្ខម្តងទៀតអំពីសាលដីកាដដែលនោះទេ។

សរុបសេចក្តីមកការចុះកម្មសិក្សាពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ព្រោះវាបានផ្តល់ឱ្យសិស្ស និស្សិតទាំងអស់យល់ដឹងច្បាស់អំពីការអនុវត្ត បទពិសោធន៍ជាក់ស្តែងជីវិតនៃការធ្វើការងារនៃមណ្ឌលកម្មសិក្សាដែលនោះជាការបំពេញទៅលើខ្លឹមសារមេរៀន និងទ្រឹស្តីដែលបានសិក្សានៅសាលានាពេលកន្លងមក ហើយយល់ពីភាពខុសគ្នា និងដូចគ្នារវាងច្បាប់ និងការអនុវត្ត។

# មតិយោបល់ និងសំណូមពរ

ដោយសង្កេតឃើញស្ថានភាពជាក់ស្តែងនៃប្រទេសជាតិយើងមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសវិស័យច្បាប់ គឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់រក្សាស្ថេរភាព និងការអភិវឌ្ឍន៍សង្គមជាតិ ហើយវាក៏ជាឧបករណ៍មួយដ៏សំខាន់សម្រាប់ការដឹកនាំក៏ដូចជាការគ្រប់គ្រងប្រទេសជាតិឱ្យមានសុខសន្តិភាពសណ្តាប់ធ្នាប់ របៀបរៀបរយល្អ។ ហេតុនេះ ដើម្បីធានាឱ្យប្រជាជនគ្រប់រូប ទោះបីជាកម្មករ និយោជិត និយោជកជាអ្នកបំរើការនៅក្នុងស្ថាប័នឯកជន ឬមួយក៏ជាមន្ត្រីរាជការសាធារណៈត្រូវតែគោរពច្បាប់ទាំងអស់គ្នា។ ជាពិសេសស្ថាប័ន ឬអង្គភាពដែលមានសមត្ថកិច្ចពាក់ព័ន្ធ ពិសេសតុលាការ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តច្បាប់បានត្រឹមត្រូវ និងមានប្រសិទ្ធិភាព។ ជាពិសេសនោះគឺចៅក្រមដែលជាអ្នកកាត់សេចក្តីតំណាងឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពី អគតិទាំង៤ នៅក្នុងពេលដែលខ្លួនធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តី។ អគតិទាំងនោះរួមមាន ឆន្ទាគតិ សេចក្តីលំអៀងព្រោះស្រឡាញ់ ទោសាគតិ សេចក្តីលំអៀងព្រោះស្អប់ មោហាគតិ សេចក្តីលំអៀងព្រោះល្ងង់ ភយាគតិ សេចក្តីលំអៀងព្រោះខ្លាចបុណ្យ ខ្លាចអំណាច ឬខ្លាចគតិ។ ចំពោះប្រព័ន្ធតុលាការ គួរគប្បីខិតខំធ្វើយ៉ាងណាបង្កើតឱ្យមានចៅក្រមដែលត្រូវទទួលបន្ទុកជំនុំជម្រះតាមផ្នែកនៃរឿងក្តីតែមួយជំនាញបានហើយ ដូចជាចៅក្រម ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម ផ្នែកការងារដែលនៅក្នុងច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ក៏បានកំណត់អំពីសមត្ថកិច្ចជំនាញនៃផ្នែកនីមួយៗផងដែរនោះ។ ការបែងចែកបែបនេះ គឺក្នុងគោលបំណងដើម្បីធានាការវិនិច្ឆ័យរឿងក្តីនឹងកាន់តែមានសុក្រឹតភាពដែលភាគីទាំងសងខាងអាចទទួលយកបាន និងមានការស្ងប់ចិត្តទៅនឹងសេចក្តីសម្រេចនេះ។

# ឯកសារយោង

- **ឯកសារជាភាសាខ្មែរ**
- **រដ្ឋធម្មនុញ្ញ**

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស. ១៩៩៣

- **ច្បាប់ និងអនុក្រឹត្យ**

-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

-ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

-ច្បាប់ ស្តីពី ការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣

-ច្បាប់ ស្តីពី ការរៀបចំតុលាការប្រជាជនបដិវត្តខេត្តក្រុង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០

-ច្បាប់ ស្តីពី នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣

-ច្បាប់ ស្តីពី ការរៀបចំស្ថាប័នតុលាការ និងអយ្យការចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

-ច្បាប់ ស្តីពី ការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

-ច្បាប់ ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៤

-ច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, លេខ នស/រកម/០៧១៤/០១៧, ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

-ច្បាប់ ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

-អនុក្រឹត្យ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល លេខ ២៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦

- **សេចក្តីសម្រេច និងដីកាសម្រេច**

-សេចក្តីសម្រេច ស្តីពី ការផ្ទេរការគ្រប់គ្រងកិច្ចការរដ្ឋបាលតុលាការដល់ការិយាល័យជំនាញនៃអគ្គលេខាដ្ឋានរដ្ឋបាលតុលាការកំពូល លេខ៣៤៩/១៦ តកក.រ.ប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

-សេចក្តីសម្រេច ស្តីពី ការបែងចែកភារកិច្ច និងការទទួលខុសត្រូវ នៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល លេខ ២២៤/១៦ តកក.សសរ

-ដីកាសម្រេច ស្តីពី ការបែងចែកសំណុំរឿង និងការចាត់ចែងរដ្ឋបាល រឿងក្តីព្រហ្មទណ្ឌ លេខ ៥៥៤ តកក.២០១៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ។

-ដីកាសម្រេច ស្តីពី ការកែសម្រួលដីកាសម្រេចលេខ ៥៧៣ តកក.២០១៦ ចុះថ្ងៃទ២៩ ខែធ្នូ ឆ្នាំ២០១

-ដីកាសម្រេចលេខ ៥៥៤ តកក.២០១៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ។

- **សៀវភៅ និងឯកសារផ្សេងៗ**

-សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត រក្សាសិទ្ធិគ្រប់យ៉ាង ឆ្នាំ២០១៥

-សៀវភៅស្រាវជ្រាវ មរតកយុត្តិខ្មែរ ដោយ លោកបណ្ឌិត ហ៊ែល ចំរើន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៩

-សៀវភៅ ប្រវត្តិគំនិតនយោបាយ និទទ្រឹស្តីរដ្ឋ ដោយ បណ្ឌិត ឈុន ណារ៉េត ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២

-របាយការណ៍ សន្និបាត របស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ប្រចាំឆ្នាំ២០១៩

-វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពផ្សាយលើកទី៤ ព.ស.២៥១១ គ.ស.១៩៦៧

-គេហទំព័រផ្លូវការ www.supremecourt.gov.kh

-ប្រព័ន្ធទំនាក់ទំនងសង្គម តុលាការកំពូល មានឈ្មោះផ្លូវការ "តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល"

- **ឯកសារជាភាសាបរទេស**

-សៀវភៅ THE SPIRIT OF LAWS របស់លោក ម៉ុង តេស្គីយើ (MONTESQUIEU) ដែលត្រូវបានបោះពុម្ពនៅឆ្នាំ១៧៤៨ ។

-សៀវភៅ The Treaties of Government 1690 របស់លោក ចន ឡុក (JOHN LOCKE) ដែលត្រូវបានបោះពុម្ពលើកទីមួយនៅឆ្នាំ១៦៩០។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ I

## លំហូរនីតិវិធីរឿងក្ដីព្រហ្មទណ្ឌនៅតុលាការកំពូល



<u>**ឧបសម្ព័ន្ធ II**</u>

<u>**អង្គការលេខរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល**</u>



បណ្តឹងសាទុក្ខរបស់

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

លេខ ....................មអក

## បណ្តឹងសាទុក្ខ

-**យោង**តាមមាត្រា៤១៧ មាត្រា៤១៨ មាត្រា៤១៩ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-**បានឃើញ** សាលដីកាលេខ......ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់សាលាឧទ្ធរណ៍

**ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល**

**យល់ឃើញថា**

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................។

## ហេតុដូច្នេះ

អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល សម្រេចធ្វើបណ្តឹងសាទុក្ខនឹងសេចក្តីសម្រេចត្រង់ចំណុច...........នៃសាលដីកាលេខ.....ចុះថ្ងៃទី.....ខែ........ឆ្នាំ...........របស់សាលាឧទ្ធរណ៍ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធានសាលាឧទ្ធរណ៍** ចាត់ការតាមនីតិវិធី ។

ធ្វើនៅថ្ងៃទី.....ខែ........ឆ្នាំ..........

ដីកាចាត់តាំងចៅក្រមរបាយការណ៍ (បណ្តឹងសាទុក្ខពីសាលដីកាសភាព្រហ្មទណ្ឌ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣❖៧៧៧

**តុលាការកំពូល**

៣៣❖៧៧

សភាព្រហ្មទណ្ឌ

លេខ៖ ....................ចត

**ដីកាចាត់តាំង**

**ប្រធានសភាព្រហ្មទណ្ឌ**

-**បានឃើញ** ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

-**បានឃើញ** មាត្រា ៤៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ...ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......របស់តុលាការកំពូល

**សម្រេចចាត់តាំង**

លោក/លោកស្រី.....................................ជាចៅក្រមរបាយការណ៍ដើម្បីពិនិត្យអំពីទម្រង់ និង គតិច្បាប់នៃសំណុំរឿងព្រហ្មទណ្ឌខាងលើ និងសាលដីកាលេខ.......ចុះថ្ងៃទី.....ខែ........ឆ្នាំ..........របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ហើយធ្វើរបាយការណ៍សន្និដ្ឋានវាយតម្លៃលើអង្គច្បាប់ និងចង្អុលប្រាប់នូវវិធានការដោះស្រាយផ្សេងៗ ដើម្បីដាក់ជូនតុលាការកំពូលជំនុំជម្រះ ។

ធ្វើនៅថ្ងៃទី.....ខែ........ឆ្នាំ..........

**អគ្គព្រះរាជអាជ្ញា**

សារណាការពារបណ្ដឹងសាទុក្ខរបស់

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ:.......................

ចុះថ្ងៃទី...ខែ......ឆ្នាំ.......

# សារណាការពារបណ្ដឹងសាទុក្ខ

-យោងលិខិតជូនដំណឹងឱ្យដាក់សារណាការពារលេខ........តកក.សព្រទចុះថ្ងៃទី.....ខែ........ឆ្នាំ...........របស់ក្រឡាបញ្ជីតុលាការកំពូល

-យោងបណ្ដឹងសាទុក្ខលេខ.......ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

-ក្រោយពីបានពិនិត្យលើសំណុំរឿងព្រហ្មទណ្ឌលេខ.......ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់តុលាការកំពូល និងសាលដីកាព្រហ្មទណ្ឌលេខ.......ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់សាលាឧទ្ធរណ៍ ឃើញថា:

អង្គហេតុ៖ (សង្ខេបអង្គហេតុស្ដាព) ........................................................................................................................................................................................................................................។

